# ឯកសារណែនាំ
# ស្តីពី
# ការចិញ្ចឹមមាន់នៅជនបទ និង
# ចំណេះដឹងហិរញ្ញវត្ថុ

## សម្រាប់កសិករចិញ្ចឹមមាន់តាមជនបទក្នុងប្រទេសកម្ពុជា



សមាគមបណ្ដាញកសិករ និងធម្មជាតិ

FARMER AND NATRUE NET ASSOCIATION (FNN)

# មាតិកា


**ផ្នែកទី១ ការចិញ្ចឹមមាន់នៅជនបទ** ........ 1

**១. សប្តាហ៍ដំបូងៗនៃជីវិតមាន់មានសារៈសំខាន់ណាស់** ........ 1

១.១. តើកូនមាន់ត្រូវការអ្វីខ្លះនៅប៉ុន្មានសប្តាហ៍ដំបូងៗ? ........ 2

១.២. ទ្រុង ........ 3

**២. ជីវសុវត្ថិភាព** ........ 5

២.១. វិធានការការពារភ្នាក់ងារបង្កជំងឺ ដើម្បីបន្តជីវិតកសិដ្ឋាន ........ 5

២.២. ការការពារកសិដ្ឋានពីភ្នាក់ងារបង្ករោគ ........ 6

២.៣. ការពារមាន់មិនឲ្យឆ្លងជំងឺគ្នា ........ 7

**៣. ការសាងសង់ទ្រុង** ........ 8

៣.១. តើមាន់ត្រូវការអ្វី? ........ 9

៣.២. តើកសិករចង់បានអ្វី? ........ 12

**៤. ចំណី** ........ 12

៤.១. ចំណីដែលផលិតនៅតាមផ្ទះ? ........ 13

៤.២. ទឹក ........ 15

**៥. ភាពតានតឹង (ស្ត្រេស) ដោយកំដៅ** ........ 15

៥.១. ការធ្វើឲ្យកំដៅខ្លួនមាន់ថយចុះ ........ 16

៥.២. ការកាត់បន្ថយភាពតានតឹង(ស្ត្រេស)ដោយកំដៅ ........ 16

**៦. ការភ្ញាស់កូនមាន់** ........ 19

៦.១.ការរៀបចំភ្ញាស់កូនមាន់តាមបែបធម្មជាតិ ........ 19

៦.២.ការភ្ញាស់កូនមាន់តាមបែបសិប្បនិម្មិត ........ 19

**៧. សុខភាព និងការចាក់វ៉ាក់សាំង** ........ 20

**ផ្នែកទី២ ចំណេះដឹងហិរញ្ញវត្ថុ** ........ 22

**១. សេចក្តីណែនាំពីចំណេះដឹងហិរញ្ញវត្ថុ** ........ 22

១.១. និយមន័យចំណេះដឹងហិរញ្ញវត្ថុ ........ 22

១.២. សារៈសំខាន់នៃចំណេះដឹងហិរញ្ញវត្ថុ ........ 22

**២. ការកត់ត្រាចំណូល ចំណាយសម្រាប់កសិករ** ........ 22

២.១. ប្រភេទនៃកំណត់ត្រាដែលត្រូវរក្សាទុក ........ 23

២.២. អត្ថប្រយោជន៍នៃការរក្សាកំណត់ត្រាប្រកបដោយប្រសិទ្ធភាព ........ 23

**៣. ការរៀបចំថវិកាសម្រាប់កសិដ្ឋាន និងគ្រួសារ** ........ 23

៣.១. សារៈសំខាន់នៃការគ្រោងថវិកា ......................................... 23
៣.២. ប្រភេទថវិកា ......................................... 24
៣.៣. ការរៀបចំថវិកាសម្រាប់កសិដ្ឋាន និង គ្រួសារ ......................................... 24
ក. គំរូថវិកាសម្រាប់កសិដ្ឋានចិញ្ចឹមមាន់សាច់ ......................................... 25
ខ. គំរូថវិកាសម្រាប់គ្រួសារ ......................................... 26
**៤. ការវិភាគហិរញ្ញវត្ថុសម្រាប់ធ្វើការសម្រេចចិត្ត** ......................................... 27
៤.១ ទិដ្ឋភាពទូទៅនៃគំនិតហិរញ្ញវត្ថុ ......................................... 27
**៥. ការគ្រប់គ្រងហានិភ័យ និងផែនការអភិវឌ្ឍន៍** ......................................... 29
**៦. ការអនុវត្តចំណេះដឹងហិរញ្ញវត្ថុសម្រាប់ភាពជោគជ័យនៃកសិដ្ឋាន** ......................................... 30
៦.១ ទម្រង់សៀវភៅកត់ត្រាសាច់ប្រាក់ ......................................... 30
៦.២ ទម្រង់កត់ត្រារបាយការណ៍ ចំណូល-ចំណាយ សម្រាប់ផលិតកម្មមាន់ ......................................... 31
៦.៣ ទម្រង់គណនាអត្រាការ (%) ប្រាក់ចំណេញ ......................................... 32
៦.៤ គម្រូកត់ត្រាប្រតិបត្តិការ ក្នុងកសិដ្ឋានចិញ្ចឹមមាន់ ......................................... 33
៦.៥ ទម្រង់ថវិកាប្រចាំឆ្នាំ សម្រាប់ផលិតកម្មមាន់ ......................................... 34
៦.៦ ទម្រង់កត់ត្រាថវិកា សម្រាប់វដ្តផលិតកម្មមាន់ ......................................... 36

## បុព្វបទ

ឯកសារសង្ខេបនេះចងក្រងឡើង សម្រាប់បណ្តុះបណ្តាលកសិករចិញ្ចឹមមាន់ក្នុងស្រុកដែលមានទម្ងន់ប្រមាណ ពី ១,៣ ទៅ ១,៥ គីឡូក្រាម។ ឯកសារនេះអាចត្រូវបានប្រើប្រាស់ ដោយគ្រូបណ្តុះបណ្តាលរបស់សមាគមបណ្តាញកសិករ និងធម្មជាតិ ( Farmers and Nature Net Association - FNN ) ដើម្បីបង្រៀនដល់កសិករលើការផ្តល់ចំណី/ទឹក ការថែទាំអនាម័យមាន់ពិសេសសម្រាប់កូនមាន់ នៅសប្តាហ៍ដំបូងៗ ហើយកសិករក៏អាចប្រើប្រាស់ឯកសារនេះជាមគ្គុទ្ទេសក្នុងការចិញ្ចឹមមាន់ផងដែរ។

# ផ្នែកទី១ ការចិញ្ចឹមមាន់នៅជនបទ

## ១. សប្តាហ៍ដំបូងៗនៃជីវិតមាន់មានសារៈសំខាន់ណាស់

- នៅពេលដែលកូនមាន់ញាស់ វានៅតែងាយរងគ្រោះ ដោយសារប្រព័ន្ធភាពស៊ាំ ដើម្បីការពារខ្លួនពីជំងឺនានា មិនទាន់ត្រូវបានលូតលាស់បានរឹងមាំនៅឡើយ។ ប្រព័ន្ធរំលាយអាហារក៏ត្រូវការលូតលាស់ ហើយកូនមាន់មិនអាចរក្សាសីតុណ្ហភាពក្នុងខ្លួនរបស់វាសម្រាប់សប្តាហ៍ដំបូងបានឡើយ ។

- តែក្នុងកំឡុងប៉ុន្មានសប្តាហ៍ដំបូងៗប៉ុណ្ណោះ (១ទៅ៤សប្តាហ៍) ប្រព័ន្ធរំលាយអាហារមានការរីកចម្រើន ក៏ដូចជាប្រព័ន្ធការពាររាងកាយដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺ និងធានាបាននូវវ៉ាក់សាំងឱ្យមានប្រសិទ្ធភាព។ បន្ទាប់ពីប៉ុន្មានសប្តាហ៍ដំបូងនោះ វាមិនសូវមានការរីកចម្រើនទៀតទេ។ ដូច្នេះ ប្រសិនបើកូនមាន់គ្រប់គ្រងបានល្អនៅក្នុងសប្តាហ៍ ដំបូងៗនោះ ឱកាសធ្លងជម្ងឺដល់កូនមាន់ត្រូវបានកាត់បន្ថយខ្ពស់បំផុត និងលូតលាស់លឿន។ ផ្ទុយទៅវិញ នៅពេលដែលគ្រប់គ្រងកូនមាន់មិនបានល្អក្នុងសប្តាហ៍ដំបូងៗ នោះឱកាសធ្លងជម្ងឺមកលើជីវិតកូនមាន់រស់នៅរហូតដល់ធំមានការកើនឡើង។ ដោយហេតុនេះហើយ ការគ្រប់គ្រងកូនមាន់នៅប៉ុន្មានសប្តាហ៍ដំបូងៗ គឺមានសារៈសំខាន់ណាស់។





- មាន់ទាំងអស់នៅក្នុងរូបភាពទាំងពីរខាងលើ មានអាយុ៧សប្តាហ៍ដូចគ្នា។ ពួកវាជាពូជដូចគ្នា ញាស់នៅតំបន់តែមួយ ក្នុងថ្ងៃតែមួយ។ មាន់នៅខាងឆ្វេងគ្រប់គ្រងបានល្អ មានសុខភាពល្អ និង លូតលាស់បានល្អ។ មាន់នៅខាងស្តាំគ្រប់គ្រងមិនបានល្អ ហើយមិនលូតលាស់ ដោយសារតែមាន់នេះ មានអាយុ៧សប្តាហ៍ហើយ សូម្បីតែអាហារបំប៉ន និងការគ្រប់គ្រងមិនបានល្អ វាធ្វើឱ្យការលូតលាស់មិនប្រសើរឡើងនោះទេ ព្រោះប្រព័ន្ធរំលាយអាហារ និងប្រព័ន្ធការពារជំងឺមានការរីកចម្រើនតែនៅក្នុងសប្តាហ៍ដំបូងតែប៉ុណ្ណោះ។ ដូច្នេះហើយ យើងត្រូវយកចិត្តទុកដាក់ក្នុងការថែទាំ និងការផ្តល់ចំណីដែលមានគុណភាពខ្ពស់ដល់កូនមាន់នៅក្នុងសប្តាហ៍ដំបូងៗ ជារឿងមួយសំខាន់បំផុត ដែលកសិករយើងគ្រប់រូបត្រូវតែអនុវត្ត។

## ១.១. តើកូនមាន់ត្រូវការអ្វីខ្លះនៅប៉ុន្មានសប្តាហ៍ដំបូងៗ?

### ១.១.១. អនាម័យ

កូនមាន់ទើបញាស់ តែងតែមានទម្ងន់ចាប់ពី៤០ក្រាម ហើយ ប្រព័ន្ធភាពស៊ាំ ដើម្បីការពារជម្ងឺនានាមិនទាន់មានការលូតលាស់ខ្លាំងនៅឡើយទេ។ ដូចនេះ ពួកវាងាយរងគ្រោះណាស់ដោយសារការឆ្លងជំងឺផ្សេងៗ។



អាស្រ័យហេតុនេះ សូមឲ្យប្រាកដថា បរិយាកាសរស់នៅរបស់វាត្រូវយកចិត្តទុកដាក់ឱ្យបានល្អ (ទ្រុង ឧបករណ៍ផ្តល់ចំណីទឹក និងការផ្តល់កំដៅ.....) គឺត្រូវសំអាតឲ្យបានស្អាតល្អ ហើយត្រូវប្រាកដថាអ្វីៗដែលចូលក្នុងបរិវេនទ្រុង ក៏ត្រូវតែស្អាត មិនមានមេរោគឆ្លងនោះទេ។ សូមមើលផ្នែកទី២ ស្តីពីជីវសុវត្ថិភាពផងដែរ ។

### ១.១.២. ទឹក

គុណភាពទឹក និងសីតុណ្ហភាពមានសារៈសំខាន់ជាងគុណភាពចំណី។ ទឹកនៅក្នុងស្នូកសម្រាប់ឱ្យមាន់ផឹកគឺត្រូវតែជាទឹកស្អាតល្អគ្មានមេរោគ ដែលកសិករត្រូវតែយកចិត្តទុកដាក់ជាចាំបាច់។ កិច្ចការនេះមិនគ្រាន់តែត្រូវការទឹកដែលមានគុណភាពល្អប៉ុណ្ណោះទេ គឺត្រូវការស្នូកទឹកស្អាតទៀតផង។ នៅពេលទឹកត្រូវបាន



ចាក់បំពេញចូលក្នុងស្នូកទឹក គឺត្រូវធានាថាជាទឹកមានគុណភាពល្អគ្មានមេរោគ លើកលែងតែស្នូកទឹកនោះមិនស្អាត។ ប្រសិនបើកសិករមិនបានចាប់អារម្មណ៍លាងសំអាតស្នូកទឹក នោះស្នូកទឹកនឹងឡើងស្រទាប់ស្នឹម ឬដុះស្លែ ដែលមានបាក់តេរីលាក់ខ្លួននៅទីនោះ និងអាចចម្លងមេរោគដល់កូនមាន់។ ក្នុងកំឡុងពេល សប្តាហ៍ដំបូងៗនៃជីវិតមាន់ យើងត្រូវលាងសម្អាតស្នូកទឹកឲ្យបានស្អាតល្អយ៉ាងហោចណាស់ម្តងក្នុងមួយថ្ងៃ។ យើងត្រូវដាក់ស្នូកទឹកនៅកន្លែងដែលកូនមាន់ងាយស្រួលចូលទៅផឹក។ សីតុណ្ហភាពទឹកសម្រាប់មាន់ផឹកក៏ជាកត្តាសំខាន់ដែរ។ ក្នុងប៉ុន្មានថ្ងៃដំបូង កូនមាន់ត្រូវការកំដៅប្រមាណ ៣២ ទៅ ៣៧អង្សាសេ ដូច្នេះទឹកក្នុងស្នូកក៏នឹងឡើងកំដៅយ៉ាងឆាប់រហ័សទៅតាមសីតុណ្ហភាពបរិយាកាសនោះផងដែរ។ ទោះជាយ៉ាងណាក៏ដោយ នៅពេលដែលទឹកក្នុងស្នូកឡើងកំដៅស្មើនឹងសីតុណ្ហភាពបរិយាកាសខាងក្រៅ នោះកូនមាន់នឹងផឹកទឹកតិចជាងតម្រូវការ។ ដូចនេះ យើងត្រូវធ្វើការផ្លាស់ប្តូរទឹកជាច្រើនដងក្នុងមួយថ្ងៃ ព្រោះកូនមាន់ចូលចិត្តផឹកទឹកក្នុងកម្រិតសីតុណ្ហភាព**២៤អង្សាសេ**។

### ១.១.៣. ចំណី

វាមានសារៈសំខាន់ណាស់ក្នុងការផ្តល់ចំណីឱ្យកូនមាន់ស៊ី គឺជាចំណីប្រកបដោយគុណភាព (ចំណីក្រុមហ៊ុន) ពិសេសក្នុងពេលប៉ុន្មានសប្តាហ៍ដំបូងៗ។ តែចំណីប្រភេទនេះវាមានតម្លៃថ្លៃ ប៉ុន្តែកូនមាន់មិនស៊ីច្រើនដូចមាន់ធំនោះទេ។ រយៈពេល ៥សប្តាហ៍ដំបូង កូនមាន់អាចស៊ីចំណីអស់ប្រហែលពី៧០០ ទៅ ៨០០ក្រាម ក្នុង១ក្បាល ។ ចំណីមួយបាវ ៣០គីឡូក្រាម អាចផ្តល់ឲ្យកូនមាន់ស៊ីបានរហូតទៅដល់ពី ៣៥ ទៅ៤៥ក្បាល ក្នុងរយៈពេល៥សប្តាហ៍ដំបូង។ ថាសស្តើងៗអាចត្រូវបានប្រើជាឧបករណ៍សម្រាប់ដាក់ចំណី ប៉ុន្តែគេក៏អាចក្រាលក្រដាសលើកម្រាលទ្រុង ហើយដាក់ចំណីតិចៗឱ្យកូនមាន់ស៊ី តែដាក់ច្រើនដងក្នុង១ថ្ងៃ។ កូនមាន់ចូលចិត្តស៊ីចំណីលើកម្រាល ហើយចំនុចសំខាន់នោះ គឺការយកកូនមាន់មកឱ្យស៊ីចំណីឱ្យបានលឿន បំផុតក្នុងថ្ងៃដំបូង។ បន្ទាប់២ ទៅ៣ថ្ងៃមក អ្នកគ្រាន់តែដាក់ចំណីនៅលើថាសស្តើង ឬស្នូកចំណីសម្រាប់កូនមាន់ ព្រោះចំណីនៅលើកម្រាលនឹងកខ្វក់នៅពេលដែលកូនមាន់កាន់តែធំ។

## ១.២. ទ្រុង

នៅសប្តាហ៍ដំបូង កូនមាន់ត្រូវការទ្រុងទំហំ ប្រហែល**កន្លះម៉ែត្របួនជ្រុង**សម្រាប់កូនមាន់**៥០ក្បាល**។ នៅសប្តាហ៍ទី ២ កូនមាន់ត្រូវកាទំហំទ្រុង១ម៉ែត្របួនជ្រុងសម្រាប់កូនមាន់**៥០ក្បាល**។ ក្រៅពីកន្លែងនេះពួកវាត្រូវការកន្លែងដែលមានក្រាលអង្កាម ឬក្រដាសនៅពីលើ។ ជាការពិតណាស់ ទ្រុងសម្រាប់កូនមាន់ត្រូវតែស្អាត និងគ្មានមេរោគ។ សូមមើលផ្នែក៣ ការសាងសង់ទ្រុងមាន់។

### ១.២.១. សីតុណ្ហភាព

ក្នុងអំឡុងពេលសប្តាហ៍ដំបូង កូនមាន់មិនអាចរក្សាសីតុណ្ហភាពរាងកាយបានល្អនោះទេ។ សីតុណ្ហភាពបរិយាកាសដែលកូនមាន់ត្រូវការចាំបាច់គឺពី ៣២-៣៧អង្សាសេ ហើយជាពិសេសកម្រាលគួរតែមានកំដៅយ៉ាងតិច **២៨អង្សាសេ** វាមិនគួរឱ្យមានភាពត្រជាក់ពេកនោះទេ។ ប្រសិនបើសីតុណ្ហភាពធ្លាក់ចុះកូនមាន់មិនសូវមានចលនា(កូនមាន់នៅផ្តុំគ្នា) ហើយមិនសូវស៊ីចំណីនោះទេ



ដែលជាកត្តារាំងដល់ការលូតលាស់របស់មាន់ក្នុងសប្តាហ៍ដំបូងនេះ។ ជាពិសេសពេលយប់ និងព្រឹកព្រលឹម វាអាចត្រជាក់ពេកសម្រាប់កូនមាន់ ហើយនៅពេលដែលឧបករណ៍/ម៉ាស៊ីនកម្តៅមិនអាចរកបាន អ្នកគួរតែពិចារណាដាក់កូនមាន់នៅក្នុងប្រអប់/ឡាំងស្អាតនៅពេលយប់ ឬពេលអាកាសធាតុចុះត្រជាក់។

រូបភាពខាងឆ្វេង បង្ហាញពីចង្កៀងកំដៅកូនមាន់ដែលមានអំពូលជាប្រភពផ្តល់កំដៅ។ កូនមាន់អាចផ្លាស់ទីទៅជិត ឬ ឆ្ងាយពីប្រភពកំដៅតាមតម្រូវការរបស់ពួកវា។ ស្នូកទឹក និងស្នូកចំណីត្រូវបានរក្សាទុកនៅចម្ងាយសមស្របពីប្រភពកំដៅ ដើម្បីការពារកុំឲ្យទឹកឡើងកំដៅ។ ទោះបីជាប្រភពកំដៅត្រូវបានបិទក៏ដោយ ក៏កូនមាន់នៅតែចូលចិត្តដេកនៅក្រោមចង្កៀងកំដៅ ព្រោះធ្វើឱ្យពួកវាមានអារម្មណ៍ថាមានសុវត្ថិភាព ។

### ១.២.២. ពន្លឺ

មាន់ស៊ីចំណីតែពេលមានពន្លឺគ្រប់គ្រាន់ ហើយវាមានសារៈសំខាន់ណាស់សម្រាប់កូនមាន់ស៊ីចំណីឲ្យបានច្រើនក្នុងរយៈពេល២សប្តាហ៍ដំបូង។ ការផ្តល់ពន្លឺនៅពេលយប់ វានឹងផ្តល់ឱកាសច្រើនឲ្យកូនមាន់បានស៊ីចំណី ផឹកទឹក និង ការលូតលាស់រាងកាយរបស់ពួកវាបានល្អ។ បន្ទាប់ពីប៉ុន្មាន២សប្តាហ៍ដំបូងនេះ ពួកវាមិនត្រូវការពន្លឺនៅពេលយប់ទៀតទេ ទោះបីយ៉ាងណាក៏ដោយ ប្រសិនបើអ្នកចង់ឱ្យមាន់របស់អ្នកលូតលាស់លឿន អ្នកត្រូវប្រាកដថា កូនមាន់រស់នៅក្នុងភាពងងឹតរយៈពេលត្រឹម**តែ ៤ ម៉ោងប៉ុណ្ណោះ គឺចាប់ពីម៉ោង 6 ល្ងាច ដល់ម៉ោង 10 យប់។** (សូមអាន ផ្នែកទី៥ ភាពតានតឹងដោយកំដៅ)

### ១.២.៣. គ្មានភាពតានតឹង

មាន់ទាំងអស់ ប៉ុន្តែកូនមាន់ពិតជាងាយនឹងស្ត្រេស ដែលនាំឱ្យមានបញ្ហាក្នុងការលូតលាស់ នឹងងាយកើតជំងឺផ្សេងៗ។ ស្ត្រេសកើតចេញពី ពន្លឺ (ភ្លឺពេក ឬប្រែប្រួលពន្លឺ) សំលេងរំខាន ការគ្រប់គ្រង ការផ្លាស់ប្តូរអាកាសធាតុភ្លាមៗ ការផ្តល់ចំណីមិនគ្រប់គ្រាន់ កន្លែងរស់នៅតូចចង្អៀត គ្មានខ្យល់បរិសុទ្ធចេញចូលបានគ្រប់គ្រាន់ ការប៉ះពាល់នឹងជំងឺ។ល។

### ១.២.៤. ការរស់នៅជាមួយមេមាន់ដែលភ្ញាស់ពួកវា

នៅពេលដែលពងមាន់ញាស់**ដោយមេក្រាប**(មិនភ្ញាស់តាមបែបសិប្បនិម្មិត) កូនមាន់រស់នៅជាមួយមេរបស់វានៅក្នុងសប្តាហ៍ដំបូង បន្ទាប់មកត្រូវបំបែកចេញពីមេរបស់ពួកវា។ ការធ្វើបែបនេះ វាមានគុណសម្បត្តិ និងគុណវិបត្តិ។ នៅពេលកូនមាន់នៅជាមួយមេវា មេមាន់នឹងក្រុងកូនធ្វើជាជម្រក និងផ្តល់កំដៅដល់កូនមាន់។ ទោះជាយ៉ាងណាក៏ដោយ នៅពេលកូនមាន់នៅជិតមាន់ពេញវ័យ វាក៏មានហានិភ័យដល់សុខភាពផងដែរ ព្រោះកូនមាន់មិនទាន់មានការការពារប្រឆាំង នឹងភ្នាក់ងារបង្កជំងឺ ខណៈមាន់ពេញវ័យគឺធន់ទ្រាំនឹងជំងឺ។ នៅពេលដែលមេមាន់បណ្តើរកូន មេមាន់នឹងបង្ហាញកូនមាន់ពីកន្លែងដែលត្រូវរកចំណីស៊ី ប៉ុន្តែក៏បង្ហាញពួកវាទៅកាន់មេរោគ និងសត្វសាហាវផ្សេងទៀតផងដែរ។ ដើម្បីការពារហានិភ័យទាំងនេះ កូនមាន់គួរតែនៅកន្លែងដែលមានសុវត្ថិភាពដាច់ដោយឡែកទៅតាមអាយុ និងកន្លែងស្អាតឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន។



កូនមាន់ត្រូវបានការពារដោយមេរបស់វា។ មេមាន់អាចផ្តល់កំដៅឲ្យកូនរបស់វាបាន ប៉ុន្តែបរិស្ថានជុំវិញវាមិនមានអនាម័យ មានភ្នាក់ងារបង្កជំងឺច្រើនដែលប៉ះពាល់ដល់សុខភាពមាន់ សូមមើលរូបខាងលើ ស្នូកទឹកមានភាពកខ្វក់ណាស់។



កូនមាន់ត្រូវបានបំបែកចេញពីមេរបស់វា។ មេរបស់វាមិនអាចក្រុងកូនដើម្បីផ្តល់កំដៅបានទេ។ បរិយាកាសមានអនាម័យ តែបើមេមាន់មានផ្ទុកមេរោគ ក៏វានៅតែឆ្លងដល់កូនមាន់ដែរ។

ការបំបែកកូនមាន់ចេញពីមេមាន់ ហើយដាក់កូនមាន់នៅកន្លែងដែលមានបរិស្ថានស្អាត ជាធម្មតាវាផ្តល់នូវអត្រាងាប់តិចជាងមុន ទោះបីតម្រូវឱ្យមានការយកចិត្តទុកដាក់បន្ថែមទៀតពីកសិករក៏ដោយ។

## ២. ជីវសុវត្ថិភាព

ជីវសុវត្ថិភាពមានន័យយ៉ាងសាមញ្ញថាៈ តើយើងត្រូវធ្វើអ្វីខ្លះ ដើម្បីកុំឲ្យជំងឺចូលក្នុងកសិដ្ឋានចិញ្ចឹមសត្វ។ វិធានការជីវសុវត្ថិភាពគឺសំដៅទៅលើ ការការពារភ្នាក់ងារបង្កជំងឺ ហៅថា ភ្នាក់ងារបង្កជំងឺ ដូចជាបាក់តេរី វីរុស ផ្សិត និងប៉ារ៉ាស៊ីត ចូលក្នុងហ្វូងមាន់ ។ ការធ្វើអនាម័យ និងការចាក់វ៉ាក់សាំងបានត្រឹមត្រូវជាប្រចាំ គឺជាសកម្មភាពមួយសំខាន់បំផុត។ ប្រាកដណាស់ មិនមែនគ្រប់ជំងឺទាំងអស់អាចការពារបានដោយការចាក់វ៉ាក់សាំង និងធ្វើអនាម័យល្អនៅកសិដ្ឋាននោះទេ។ ឧ.កង្វះសារជាតុរ៉ែ ឬវីតាមីននៅក្នុងចំណីក៏អាចបង្កឱ្យមានជំងឺផងដែរ ប៉ុន្តែហានិភ័យនៃជំងឺឆ្លងអាចត្រូវបានកាត់បន្ថយយ៉ាងច្រើនដោយវិធានការជីវសុវត្ថិភាព។

*ត្រូវដឹងថា ការពារជំងឺប្រសើរជាងព្យាបាល*

- សម្រាប់ជំងឺកើតលើមាន់មួយចំនួន ស្ទើរតែមិនមានថ្នាំព្យាបាលនោះទេ។
- ទោះបីមាន់បានធូរស្រាលពីជំងឺក៏ដោយ ក៏វានៅរងទុក្ខ ឬការលំបាកដែរ ដែលធ្វើឱ្យការលូតលាស់របស់មាន់មិនបានល្អ។

### ២.១. វិធានការការពារភ្នាក់ងារបង្កជំងឺ ដើម្បីបន្តជីវិតកសិដ្ឋាន

ក្នុងអំឡុងពេលផលិតកម្ម មេរោគមួយចំនួននឹងស្ថិតនៅក្នុងកសិដ្ឋានដោយជៀសមិនរួចនោះទេ។ ប្រសិនបើភ្នាក់ងារបង្កជំងឺមានកំណត់ ហើយមាន់បានប៉ះពាល់ដល់ភ្នាក់ងារបង្កជំងឺទាំងនោះ វានឹងធ្វើឱ្យមានបញ្ហាឆ្លងជំងឺបានយ៉ាងលឿន។ ប៉ុន្តែប្រសិនបើ យើងយកក្រុមមាន់ថ្មីចូលមក ដោយមិនបានតាមដានឱ្យបានត្រឹមត្រូវទេ ពេលដាក់ចូលជាមួយហ្វូងមាន់ចាស់វានិងងាយឆ្លងជំងឺណាស់ ពិសេសកូនមាន់មានអាយុតិច មេរោគទាំងនេះធាប់នឹងបង្កជំងឺដល់ពួកវា។ អាស្រ័យហេតុនេះសម្ភារៈអ្វីៗដែលមានការទំនាក់ទំនងជាមួយកូនមាន់ត្រូវតែសម្អាតឲ្យបានស្អាត និងសម្លាប់មេរោគចេញឱ្យបានល្អ មុនពេលយកវាមកប្រើប្រាស់ជាមួយក្រុមមាន់ថ្មីម្តងទៀត។ ដូចជា ទ្រុងមាន់ និងសម្ភារៈបរិក្ខារ (កម្រាល ជញ្ជាំង សំបុក ប្រក់ដំបូល ស្នូកទឹក ស្នូកចំណី បរិក្ខារភ្ញាស់កូនមាន់ ដូចជាម៉ាស៊ីនកម្តៅ ស្នូកទឹក ស្នូកចំណី ស្នាចចូកចំណី ......)។

ការសម្អាត និងការសម្លាប់មេរោគ គឺជាសកម្មភាពពីរដាច់ដោយឡែកពីគ្នា។ ជាធម្មតាថ្នាំសំលាប់មេរោគគឺមិនសូវមានប្រសិទ្ធភាពក្នុងបរិយាកាសកខ្វក់នោះទេ ដូច្នេះដំបូងត្រូវលាងសម្អាតរបស់របរនឹងទឹកសាប៊ូ បន្ទាប់ពីលាងសម្អាតហើយនោះ យើងអាចប្រើថ្នាំសម្លាប់មេរោគលើរបស់របរប្រើប្រាស់ទាំងនោះ ដូចជាទ្រុង ស្នូកចំណី ស្នូកទឹក និងបរិវេនជុំវិញទ្រុង។

### ២.២. ការការពារកសិដ្ឋានពីឆ្លាក់ងារបង្កភាគ

ជានិច្ចជាកាល កសិករត្រូវដឹងថា មានអ្នកណាខ្លះ ឬមានអ្វីខ្លះដែលមកពាក់ព័ន្ធជាមួយមាន់ពួកគាត់ ឬរបស់របរស្អាត ឬមិនមានភ្នាក់ងារបង្កពោគ ព្រោះមានមេរោគអាចចូលមកក្នុងកន្លែងចិញ្ចឹមមាន់របស់យើងតាមគ្រប់វិធីដូចខាងក្រោម៖

- ជាមួយមាន់ដែលឆ្លងមេរោគបក្សី(ព្រៃ) ឬសត្វដទៃទៀត(រួមមានសត្វឆ្កែ ឆ្មា កណ្តុរ និងសត្វល្អិត...)
  - ដូច្នេះ ចូររក្សាមាន់របស់អ្នកឱ្យឆ្ងាយពីសត្វទាំងនេះ ត្រូវប្រាកដថាសត្វចិញ្ចឹមមិនអាចនៅក្បែរទ្រុងមាន់របស់អ្នកបានទេ។ ប្រសិនបើអ្នកមានកូនមាន់ដែលមានអាយុខុសៗគ្នា អ្នកត្រូវដាក់កូនមាន់ទាំងនោះទៅតាមអាយុដាច់ដោយឡែកៗពីគ្នា។ អ្នកត្រូវដឹងថា នៅពេលដែលមាន់ដើរចេញរកចំណីស៊ីខាងក្រៅទ្រុង ពួកវាងាយ នឹងឆ្លងមេរោគ/ជំងឺផ្សេងៗ ។. ឆ្លងតាមរយៈលាមកបក្សីព្រៃ លាមកសត្វឆ្កែ សត្វឆ្មា សត្វកណ្តុរ ។
  - សត្វកកេរ(កណ្តុរ)មិនត្រឹមតែបង្កការខូចខាត និងស៊ីចំណីមាន់ប៉ុណ្ណោះទេ ប៉ុន្តែវាក៏អាចបំពុល និងបង្កជំងឺរាលដាលដល់ទៅ **៣៥ ប្រភេទ**ផ្សេងៗគ្នាទៀតផង។ ដូចនេះអ្នកត្រូវប្រាកដថា ទ្រុងមាន់ ចំណី និងទឹក ត្រូវបានការពារពីសត្វកណ្តុរទាំងនេះតាមដែលអាចធ្វើបាន។ តើដឹងទេថា សត្វកណ្តុរចូលចិត្តលាក់ខ្លួននៅក្នុងគំនរសម្ភារ ឬសំរាមស៊ុបទ្រុបណាស់ ដូច្នេះ សូមរក្សា/សំអាតកន្លែងចិញ្ចឹមមាន់របស់អ្នកឱ្យស្អាតតាមដែលអាចធ្វើទៅបាន ដោយគ្រាន់តែដាំដុះបន្លែតិចតួចនៅក្បែរនោះបានហើយ។
- ជាមួយនឹងបរិក្ខារ ឬឧបករណ៍ ឬក៏របស់របរផ្សេងទៀតនាំយកចូលក្នុងកសិដ្ឋាន ឬកន្លែងចិញ្ចឹមមាន់
  - ដូច្នេះ អ្វីៗដែលកំពុងប្រើប្រាស់ជាមួយនឹងមាន់ សូមពិចារណា និងវាយតម្លៃអំពីផលប៉ះពាល់/ហានិភ័យ តែប្រសិនបើមិនប្រាកដ សូមលាងសម្អាតវាឲ្យបានស្អាត។
- ជាមួយនឹងកម្ទេចកម្ទីដែលបានជ្រុះលើកម្រាល និងភាពកខ្វក់ដែលសល់ពីក្រុមមាន់មុនៗ
  - អាស្រ័យហេតុនេះ សូមប្រាកដថា ភាពកខ្វក់ និងកម្ទេចកម្ទីដែលបានជ្រុះក្នុងបរិវេនចិញ្ចឹមមាន់ត្រូវប្រមូលយកចេញទៅឲ្យឆ្ងាយពីទ្រុងមាន់ ហើយដុតវាចោល ។
- ជាមួយទឹក និងចំណី ក៏ដូចជាខ្យល់
  - ដូច្នេះ ត្រូវប្រាកដថា ទឹកដែលដាក់ឲ្យមាន់ផឹកគឺជាទឹកស្អាត ហើយត្រូវលាងសម្អាតស្នូកទឹកឲ្យបានញឹកញាប់ (ជាពិសេសផ្នែកខាងក្នុង)។
- ចំពោះមនុស្ស វាសំខាន់ណាស់ ព្រោះថា ការផ្ទុះជំងឺឆ្លងបក្សីមួយចំនួនគឺបណ្តាលមកពីមនុស្ស (អាចឆ្លង៨០%ទៅមាន់)។
  - នេះបញ្ជាក់ថា កសិករត្រូវដឹងជានិច្ចថា អ្នកណា ឬអ្វីដែលជាប់ពាក់ព័ន្ធជាមួយសត្វមាន់ តើវាស្អាត ឬមិនស្អាត គ្មានបង្កមេរោគឬអត់។

- ត្រូវឲ្យប្រាកដថាដៃរបស់អ្នកស្អាត រាល់ពេលចូលទ្រុងមាន់ ឬប៉ះពាល់ជាមួយរបស់របរសម្រាប់ចិញ្ចឹមមាន់ (ឧ. ស្នូកទឹក ស្នូកចំណី)
- ប្រសិនបើអ្នកត្រូវចូលក្នុងទ្រុងមាន់ សូមអ្នកប្រើ ឬពាក់ស្បែកជើងដែលអ្នកធ្លាប់ប្រើចូលក្នុងទ្រុងមាន់តែប៉ុណ្ណោះ ទោះបីជាអ្នកត្រូវចូលក្នុងរយៈពេលតែប៉ុន្មាននាទីក៏ដោយ។ អ្នកគួរព្យួរស្បែកជើងដែលអ្នកធ្លាប់ប្រើនៅក្បែរទ្វារចូលទ្រុងមាន់ ដូច្នេះអ្នកអាចប្តូរស្បែកជើងនៅមុខទ្វារទ្រុងមាន់បាននៅពេលចូល និង នៅពេលចាកចេញពីទ្រុងមាន់ ទោះបីជាមួយភ្លែតក៏ដោយ។ ការទម្លាប់ផ្លាស់ប្តូរស្បែកជើងរបស់អ្នកចូលក្នុងទ្រុងមាន់ ឬកសិដ្ឋានចិញ្ចឹមមាន់ជាប់លាប់វាជាចំណុចល្អ។ ការអនុវត្តន៍បែបនេះបានជាប់លាប់ នោះវាមានប្រសិទ្ធភាពជាងការលាងជើងដែលមានការលំបាក និងចំណាយច្រើន។

- ជាមួយនឹងខ្យល់

  ជាអកុសល ភ្នាក់ងារបង្កជំងឺមាន់មួយចំនួនមានការគំរាមកំហែងខ្លាំង ដូចជា ជំងឺញ៉ូវកាស និងគ្រុនផ្តាសាយបក្សី ដែលសាយភាយតាមខ្យល់។ ដោយសារតែទ្រុងមាន់ត្រូវការខ្យល់ចេញចូលច្រើន ដូចនេះហានិភ័យនៃជំងឺនេះតែងតែកើតមាន។ អ្នកអាចកាត់បន្ថយហានិភ័យ ដោយសង់ទ្រុងមាន់ឲ្យឆ្ងាយពីទ្រុងមាន់ផ្សេងទៀត ហើយពិចារណាពីទិសដៅខ្យល់ទូទៅ ដើម្បីកុំឲ្យខ្យល់ចេញពីទ្រុងមាន់ផ្សេងទៀតចូលក្នុងទ្រុងមាន់របស់អ្នក។

## ២.៣. ការពារមាន់មិនឲ្យឆ្លងជំងឺគ្នា

នៅពេលមានមាន់មួយ ឬពីរបីក្បាលនៅក្នុងទ្រុងមានអាការៈឈឺ កសិករប្រញាប់បំបែកពួកវាដាក់នៅទ្រុងដាច់ដោយឡែក។ ត្រូវដឹងថា សូម្បីតែពេលនៅបែកគ្នាក៏នៅតែឆ្លងទៅមាន់ផ្សេងទៀតដែរ។ ជាការពិតមាន់ភាគច្រើនឈឺ ដោយសារតែមាន់ផ្សេងទៀតក្នុងហ្វូងនោះមានជំងឺ។ មាន់ឈឺអាចរស់បាន ប៉ុន្តែសកម្មភាពរបស់មាន់ទាំងនេះ ជាធម្មតាមិនល្អនោះទេ ក្រៅពីនេះ ក្នុងអំឡុងពេលមាន់មានជំងឺ វាមានហានិភ័យធំក្នុងការឆ្លងដល់មាន់ដ៏ទៃទៀត។ ពេលជួបបញ្ហាបែបហ្នឹង កត្តាដែលល្អបំផុតនោះគឺ សំលាប់មាន់ទាំងនោះចោលហើយដុត ឬកប់ចោលឲ្យបានត្រឹមត្រូវ។

### ២.៣.១. ការបោះចោលមាន់ងាប់

ទោះបីជាមាន់បានងាប់ក៏ដោយ ពួកវានៅតែអាចបង្កគ្រោះថ្នាក់ដល់សុខភាពសម្រាប់មាន់ផ្សេងទៀត ជាពិសេស មេរោគ/ជំងឺ នឹងរីករាលដាលកាន់តែធំ ប្រសិនបើមាន់ដែលងាប់ទាំងនេះត្រូវបានបោះចោលឲ្យពពួកសត្វស៊ីសាច់ជាអាហារ ដូចជាសត្វក្អែក ស្វាំង ខ្លែង កណ្តុរ ឆ្មា ឆ្កែ និងសត្វដទៃទៀត ស៊ីមាន់ងាប់។ ដូច្នេះវាជាការសំខាន់ណាស់ ក្នុងការបោះចោលមាន់ងាប់ឲ្យបានត្រឹមត្រូវដោយការដុត ឬកប់ឲ្យបានត្រឹមត្រូវ។

## ៣. ការសាងសង់ទ្រុង

ទ្រុងដែលមានលក្ខណៈសមរម្យគឺ៖

- សង់កន្លែងដែលមានទីទួលសុវត្ថិភាព( មិនលិចទឹក និងមិនធ្លាប់កើតជំងឺឆ្លង )
- ផ្តល់បរិយាកាសដែលមានផាសុខភាពសម្រាប់សត្វមាន់
- ការពារមាន់ពីអាកាសធាតុអាក្រក់ (ដូចជា ភ្លៀង អាកាសធាតុក្តៅ/ត្រជាក់)
- ការពារមាន់ពីសត្វស៊ីសាច់ជាអាហារ និងមួយផ្នែកទៀត ប្រឆាំងនឹងភ្នាក់ងារបង្កជំងឺ/មេរោគដូចជា បាក់តេរី ផ្សិត មេរោគ

ទ្រុងដែលមានលក្ខណៈសម្បត្តិងាយស្រួលក្នុងការគ្រប់គ្រង។



ទ្រុងមាន់ដែលមានកម្រាលរនាបឈើខ្ពស់ពីដី។



ទ្រុងមាន់ដែលមានកម្រាលរឹង និងដំបូលបើកចំហ ដើម្បីធានាបាននូវលំហូរខ្យល់អតិបរមា។



ទ្រុងសម្រាប់កូនមាន់តូចៗ។

## ៣.១. តើមាន់ត្រូវការអ្វី?

### ៣.១.១. ទំហំទ្រុង

មាន់ចង់មានបរិវេណរស់នៅគ្រប់គ្រាន់ ក្នុងអំឡុងពេលកូនមាន់កើតថ្ងៃដំបូង ១ម៉ែត្រការ៉េ គឺគ្រប់គ្រាន់សម្រាប់កូនមាន់ ១០០ក្បាល ប៉ុន្តែបន្ទាប់ពីមួយសប្តាហ៍កូនមាន់ទាំងនេះនឹងត្រូវការ ២ម៉ែត្រការ៉េ។ បន្ទាប់មកកូនមាន់ ១០០ ក្បាលហ្នឹងលូតលាស់រហូតដល់ធំល្មមលក់ ត្រូវការទីធ្លា ១០ម៉ែត្រការ៉េ។ ដូច្នេះ ទ្រុងត្រូវមានទំហំ ១,២៥ ម៉ែត្រ x បណ្តោយ ៤ម៉ែត្រ គឺគ្រប់គ្រាន់សម្រាប់មាន់ ៥០ ក្បាល និង ទ្រុងមានទំហំ ទទឹង ១,៦ ម៉ែត្រ x ៦,២៥ម៉ែត្រ គឺគ្រប់គ្រាន់សម្រាប់មាន់ ១០០ ក្បាល។

### ៣.១.២. ស្នូកចំណី និងស្នូកទឹក

ស្នូកចំណី និងទឹកគួរតែមានលក្ខណៈងាយស្រួលសម្រាប់មាន់ចូលស៊ីចំណី និងផឹកទឹក ប៉ុន្តែវាមិនងាយស្រួលនោះទេ ព្រោះវាអាចកំពប់ចំណីផងដែរ។ ក្នុងអំឡុងពេលពីរសប្តាហ៍ដំបូង យើងគួរតែរៀបចំស្នូកចំណីឲ្យមាន់ងាយស្រួលចូលស៊ី ប៉ុន្តែក្រោយមកត្រូវជៀសវាងការកំពប់ចំណី ដូច្នេះត្រូវជ្រើសរើសស្នូកចំណីដែលកាត់បន្ថយការកំពប់ ហើយប្រសិនបើអាចធ្វើទៅបានដាក់ចំណីនៅលើកម្រាល ឧ.លើកម្រាលឥដ្ឋ។ អនុវត្តដូចគ្នានេះដែរចំពោះស្នូកទឹក គឺត្រូវតែមានភាពងាយស្រួលសម្រាប់មាន់ចូលផឹកទឹក ប៉ុន្តែជៀសវាងការកំពប់។ ទឹកដែលកំពប់ ជាពិសេសនៅលើកំរាលឥដ្ឋបង្កើតឲ្យមានភាពកខ្វក់ បង្កឲ្យមានបាក់តេរី និងផ្សិតរីករាលដាលកាន់តែច្រើន ។ ដូច្នេះ បន្ទាប់ពីសប្តាហ៍ដំបូង ចូរដាក់ស្នូកទឹកនៅកម្ពស់ល្មម ដើម្បីឲ្យមាន់អាចផឹកបានយ៉ាងងាយស្រួល ប៉ុន្តែមិនធ្វើឲ្យ កខ្វក់ ឬទឹកមិនស្អាតនោះទេ។

### ៣.១.៣. បង្គង

តាមធម្មជាតិ សត្វមាន់មិនចូលចិត្តសម្រាក និងដេកនៅលើកម្រាលផ្ទាល់ដីនោះទេ ប៉ុន្តែពួកវាចូលចិត្តដេកនៅលើមែកឈើ ឬបង្គង។ ជាការល្អ យើងត្រូវរៀបចំបង្គងសម្រាប់ឲ្យមាន់ដេក ដើម្បីជៀសវាងភាពតានតឹង(ស្ត្រេស)។



បង្គងសម្រាប់មាន់កូនកាត់ត្រូវការកន្លែងទំប្រហែល ១៥ សង់ទីម៉ែត្រ ក្នុងមួយចន្លោះ។ ចំណែកមាន់ក្នុងស្រុកវិញទំហំតូចជាងកន្លែងទំពី ២០ ទៅ ៣០សង់ទី ម៉ែត្រសម្រាប់មាន់គឺគ្រប់គ្រាន់ដែលមានន័យថា ប្រសិន បើអ្នកមានមាន់ ៥០ ក្បាល អ្នកត្រូវការកន្លែងសម្រាប់ធ្វើបង្គងប្រហែល៦,៥-៧ ម៉ែត្រ។បង្គងសម្រាប់យកមកធ្វើទ្រនំឲ្យមាន់ទំ គឺដើមឬស្សីដែលងាយស្រួលសម្អាត និងមានទំហំប៉ុន៣សង់ទីម៉ែត្រ គឺសមរម្យណាស់សម្រាប់ធ្វើបង្គងមាន់។

### ៣.១.៤. អាកាសធាតុល្អ

ដើម្បីការពារមាន់កុំឲ្យសើមទឹកភ្លៀង គួរធ្វើដំបូលទ្រុងកុំឲ្យសាចទឹកចូល ដោយលយចុងសំយាប ដំបូលទ្រុងទាំងសងខាងឲ្យវែង នេះក៏អាចទប់ពន្លឺព្រះអាទិត្យចូលក្នុងទ្រុងផងដែរ។ ពេលថ្ងៃក្ដៅ កូនមាន់មិនគួរត្រូវពន្លឺព្រះអាទិត្យផ្ទាល់នោះទេ ដូចនេះដំបូលដែលប្រក់ធ្លាក់ចុងសំយាបវែងនឹងមានប្រយោជន៍ ហើយទ្រុងត្រូវសង់បណ្ដោយថ្ងៃ (សូមមើលផ្នែក ៣.១.៥ ពន្លឺ)។

កន្លែងម្លប់ដែលបាំងដោយដំបូលមានសារៈសំខាន់ ដើម្បីកុំឲ្យកូនមាន់ក្ដៅពេក។ ដំបូលប្រក់ពីសង្ក័សីអាចប្រើប្រាស់បានយូរ ប៉ុន្តែវាបញ្ចេញកំដៅខ្លាំងដល់មាន់នៅក្នុងទ្រុង ជាពិសេសប្រសិនបើដំបូលទាប។ ដំបូលប្រក់ស្បូវមានផាសុកភាពជាងសម្រាប់កូនមាន់ ព្រោះវាត្រជាក់ដែលមានន័យថាទ្រុងកូនមាន់រក្សាភាពត្រជាក់នៅពេលថ្ងៃ ប៉ុន្តែក៏មានភាពកក់ក្ដៅផងដែរនៅពេលយប់ត្រជាក់។ គុណវិបត្តិមួយគឺថាវាត្រូវរុះរើជាញឹកញាប់ពិបាកសម្អាត និង សម្លាប់មេរោគ ហើយវាមានហានិភ័យទាក់ទាញសត្វកណ្ដុរ ដែលបង្កគ្រោះថ្នាក់ដល់មាន់។ ខ្យល់ចេញចូលក៏សំខាន់ដែរ ហើយជាពិសេសខ្យល់អាកាសនឹងជួយឲ្យមាន់កាត់បន្ថយកំដៅនៅពេលថ្ងៃក្ដៅ។ សម្រាប់ហេតុផលនេះ ទ្រុងមាន់គួរតែបើកចំហតាមដែលអាចធ្វើទៅបាន។ ជញ្ជាំងទ្រុងអាចត្រូវបានបាំងដោយចងសំណាញ់លួស។ សំណាញ់លួសដែលមានក្រឡាតូចវាជាការល្អ បើសំណាញ់រន្ធធំអាចឲ្យសត្វ (ដូចជាកណ្ដុរ ចាប ពស់...) ចូលបានងាយ។ ប៉ុន្តែបើសំណាញ់រន្ធតូចពេកអាចជាប់ធូលីងាយ ធ្វើឱ្យរាំងខ្យល់។ ដូចនេះ រន្ធសំណាញ់ គួមានចន្លោះពី ១,៥ សង់ទីម៉ែត្រ ទៅ ២ សង់ទីម៉ែត្រ គឺសមរម្យ។ កម្រាល/ផ្ទើក៏ត្រូវបើកចំហរផងដែរ ដើម្បីឲ្យមានខ្យល់ចេញចូល និងកាត់បន្ថយការជាប់លាមកមាន់ដែលជាកាកសំណល់មិនល្អ។ កម្រាលធ្វើពីឫស្សី គឺសមរម្យ និងល្អបំផុត។



មាន់នៅក្នុងទ្រុងនៅលើបន្ទះឫស្សី និងទុំលើបង្គង



មាន់នៅលើបន្ទះឬស្សីធំទូលាយដែល មានខ្យល់ចេញចូលបានល្អ។ សំណាញ់មួយដាក់លើបន្ទះឬស្សី ដើម្បីការពារកូនមាន់កុំឲ្យធ្លាក់តាមចន្លោះឬស្សី។



កន្លែងចិញ្ចឹមកូនមាន់ទើបនឹងញាស់ នៅខាងលើនៃកម្រាលឬស្សី។ នៅលើកម្រាលបន្ទះឬស្សី ក្រាលសំណាញ់សម្រាប់មាន់ដើរ និងនៅលើកម្រាល គេក្រាលសំណាញ់ស្អាតរួចដាក់អង្កាមពីលើ។ ប្រើបានរយៈពេលប្រហែលពីរសប្តាហ៍ ត្រូវផ្លាស់ប្តូរអង្កាម និងសំណាញ់ចេញ។

### ៣.១.៥. ពន្លឺ

ដូចដែលបានរៀបរាប់ពីមុន កូនមាន់ត្រូវការពន្លឺខ្លះ ដើម្បីស៊ីចំណី និងផឹកទឹក ប៉ុន្តែត្រូវជៀសវាងពន្លឺព្រះអាទិត្យចាំងចូលដោយផ្ទាល់ទៅក្នុងទ្រុងមាន់។ ពន្លឺព្រះអាទិត្យចាំងចូលមកដោយផ្ទាល់ ដែលមាន់មិនអាចគេចចេញទៅរកកន្លែងម្លប់នៅក្នុងទ្រុងនោះបាន វាអាចនាំឲ្យមាន់មានភាពតានតឹងច្រើន(ស្ត្រេស) និងប៉ះពាល់ដល់ដំណើរការ ឬការលូតលាស់របស់មាន់ ហើយថែមទាំងធ្វើឲ្យមាន់ចិកគ្នាយ៉ាងខ្លាំង បណ្តាលឲ្យមាន់ងាប់(ចិកគ្នាស៊ី)។




អ្នកអាចជៀសវាងពន្លឺព្រះអាទិត្យពេលថ្ងៃ និង ពេលរសៀលចាំងចូលទ្រុងខ្លាំងពេក ដោយសង់/ដាក់ទ្រុងមាន់បណ្តោយថ្ងៃ ដើម្បីឲ្យព្រះអាទិត្យពេលថ្ងៃ និង ពេលល្ងាចចាំងចូលក្នុងទ្រុងតាមរយៈច្រកចំហនៃល្វែងទទឹងទ្រុងតែប៉ុណ្ណោះ។

### ៣.២. តើកសិករចង់បានអ្វី?

ជាការពិតណាស់ កសិករចង់បានទ្រុងមាន់មួយ ដែលមាន់របស់ពួកគាត់អាចលូតលាស់លឿនដោយគ្មានបញ្ហា ប៉ុន្តែលើសពីនេះ កសិករក៏ចង់បានទ្រុងមាន់ដែលមានតម្លៃទាប ងាយស្រួលក្នុងការគ្រប់គ្រងសម្អាត និងសម្លាប់មេរោគផងដែរ។

ជំនួសឲ្យការចំណាយទុនលើទ្រុងដែលមានកម្រាលរឹង(បេតុង) "ទ្រុងកូនមាន់មួយ" ដូចបានបង្ហាញនៅមេរៀនខាងដើម នេះមានតម្លៃថោកជាង ហើយប្រសិនបើទ្រុងសម្រាប់កូនមាន់ប្រមាណ ៥០ ក្បាល ទ្រុងកូនមាន់តូចស្រដៀងគ្នាហ្នឹង ហើយអាចចល័តបានដោយមនុស្សពីរ ឬបីនាក់ គឺអាចធ្វើទៅបាន។ ចំណែកឧបករណ៍វិញ កសិករចង់បានស្នូកចំណី និងស្នូកទឹកដែលងាយគ្រប់គ្រង និងងាយសម្អាត។ ជាពិសេសស្នូកទឹកដែលត្រូវលាងសម្អាតជារៀងរាល់ថ្ងៃ។

## ៤. ចំណី

ចំណីល្អបំផុតសម្រាប់មាន់មានប្រូតេអ៊ីនដែលមានគុណភាពល្អ រវាងថាមពល វីតាមីន សារជាតុរ៉ែ ប្រូតេអ៊ីន និងសារជាតុផ្សេងៗទៀតសម្រាប់ការលូតលាស់សរុបច្រើនជាង ៣៦ សារជាតុចិញ្ចឹមបញ្ចូលគ្នា និងមានសមមាត្រសមស្រប។ សារជាតុចិញ្ចឹមទាំងអស់នេះលាយក្នុងបរិមាណត្រឹមត្រូវ គឺមាននៅក្នុងចំណីក្រុមហ៊ុន ដែលជាលក្ខខណ្ឌសម្រាប់ការលូតលាស់របស់មាន់ដោយមិនមានបញ្ហា។ ចំណីដែលមិនមានគុណភាព ពេលដែលមាន់ស៊ីទៅធ្វើឲ្យដំណើរការលូតលាស់របស់មាន់មិនបានល្អហើយក៏អាចបណ្តាលឲ្យកើតជំងឺផងដែរ។

យ៉ាងណាក៏ដោយ ចំណីដែលមានគុណភាពល្អតែងតែមានតម្លៃថ្លៃ ដូច្នេះហើយកសិករត្រូវតែចេះផ្សំចំណីជាមួយនឹងវត្ថុធាតុដើមក្នុងស្រុកដែលមានតម្លៃថោកដោយខ្លួនឯង ដែលចំណីផ្សំទាំងនេះតែងតែមានគុណភាពទាបជាងស្តង់ដា។ សម្រាប់កសិករមានភាពស្មុគស្មាញ និងវត្ថុធាតុដើមដែលមានតម្លៃថ្លៃ ក្នុងការទទួលបានគ្រឿងផ្សំទាំងអស់នេះ ដើម្បីធានាបាននូវសារជាតុចិញ្ចឹមទាំង ៣៦ នោះឲ្យបានត្រឹមត្រូវតាមបរិមាណ។

ប្រសិនបើចំណីដែលបានផ្តល់មិនបានគ្រប់គ្រាន់នោះ មាន់អាចដើររើសចំណីស៊ី ដោយសេរីនៅក្នុងបរិវេនដែលមានចំណីច្រើនសម្រាប់មាន់ មាន់ទាំងនេះប្រហែលជាអាចស្វែងរកចំណី ដូចជាសត្វល្អិតដែលមានប្រូតេអ៊ីនសំខាន់ៗ ឬគ្រាប់រុក្ខជាតិដែលមានសារជាតុរ៉ែសំខាន់ៗ និងវីតាមីនដែលមិនមាននៅក្នុងចំណីដែលបានផ្តល់ឲ្យ ដោយហេតុនេះហើយត្រូវធ្វើឲ្យប្រសើរឡើងនូវការស៊ីចំណីរបស់ពួកវា។ ទោះយ៉ាងណាក៏ដោយ មាន់ដែលរកស៊ីចំណីដោយសេរី គឺងាយរងគ្រោះដោយសត្វស៊ីសាច់ចាប់ស៊ីជាអាហារ និងឆ្លងជំងឺផងដែរ។ ប្រសិនបើមាន់អាចស៊ីចំណីដែលផ្តល់ដោយកសិករ ហើយចំណីនោះមិនមានតុល្យភាពជីវជាតិទាំងស្រុងនោះ ដំណើរការលូតលាស់នឹងរងផលប៉ះពាល់។

## ៤.១. ចំណីដែលផលិតនៅតាមផ្ទះ?

ជាពិសេសនៅក្នុងខែដំបូង ការលូតលាស់រាងកាយរបស់មាន់គឺមានសារៈសំខាន់ណាស់ ដូច្នេះហើយ សូមកសិករផ្តល់ចំណីដល់ មាន់ក្នុងរយៈពេលនេះជាមួយ នឹងចំណីដែលមានគុណភាពល្អ។ ទោះបីជា វាមានតម្លៃថ្លៃក៏ដោយ ដើម្បីការពារកុំឲ្យស្តាយក្រោយក្នុងការចិញ្ចឹមមាន់។ បន្ទាប់ពីខែដំបូងនោះ គុណភាពចំណីលាយតាមសមមាត្រក៏នៅតែជាកត្តាដ៏មានសារៈសំខាន់ ប៉ុន្តែសក្តានុពលហ្សែនរបស់មាន់ក្នុងស្រុក ដើម្បីលូតលាស់នៅមានកម្រិត ហើយឥទ្ធិពលនៃការផ្តល់ចំណីដែលមិនមានសមមាត្រសារជាតុចិញ្ចឹមពេញលិញក៏នៅមានកម្រិតផងដែរ។ ដើម្បីឲ្យច្បាស់ អ្នកអាចផ្តល់ចំណីគ្រប់ប្រភេទដល់មាន់ ហើយរំពឹងថាមាន់នឹងលូតលាស់បានល្អផងដែរ។ ប្រសិនបើអ្នកនឹងរៀបចំចំណីដោយលាយជាមួយចំណីដែលមានតម្លៃថោក អ្នកត្រូវតែព្យាយាមលាយចំណីតាមសមមាត្រ (រូបមន្ត) តាមដែលអាចធ្វើទៅបាន។

### ៤.១.១. ប្រើចំណីក្រុមហ៊ុនជាមូលដ្ឋាន

អ្នកអាចលាយចំណីក្រុមហ៊ុនជាមួយកន្ទក់ ចុងអង្ករ ម្សៅត្រី អាហារូឡាស្ងួត និងពោតកិន ប៉ុន្តែអ្នកនឹងខ្វះសារជាតុចិញ្ចឹមសំខាន់ៗ ដោយសារជាតុផ្សំទាំងនេះមិនមានផ្ទុកសារជាតុចិញ្ចឹមគ្រប់គ្រាន់នោះទេ។ ផលវិបាកនៃការខ្វះសារជាតុចិញ្ចឹមសំខាន់ៗមួយចំនួន គឺធ្វើឲ្យមាន់មានការលូតលាស់យឺត ហើយអាចទទួលរងពីជំងឺកង្វះសារជាតុចិញ្ចឹមផង។ ឧ. កង្វះវីតាមីន និងសារជាតុរ៉ែ ដែលអាចនាំឲ្យមានបញ្ហាសុខភាពជាច្រើន អ្នកអាចពិចារណាប្រើចំណីក្រុមហ៊ុនដែលមានគុណភាពលាយពី **៣០ ទៅ ៥០%** ជាមួយនឹងជាតុផ្សំចំណីក្នុងស្រុកមួយចំនួន។ ធ្វើបែបនេះ អ្នកនឹងអាចទទួលបានចំណីដែលមានគុណភាពល្អ ប៉ុន្តែសារជាតុចិញ្ចឹមទាំងអស់នឹងមាននៅក្នុងចំណី។ ដូច្នេះ អ្នកមិនអាចរំពឹងថា មានដំណើរការផលិតចំណីដូចគ្នានោះទេ បើធៀបនឹងការចិញ្ចឹមមាន់ជាមួយនឹងចំណីក្រុមហ៊ុន ប៉ុន្តែចំណីលាយខ្លួនឯងនឹងមានតម្លៃថោកជាង។

### ៤.១.២. ផលិតចំណីពេញលេញដោយខ្លួនឯង

ប្រសិនបើអ្នកមិនចង់ទិញចំណីពីក្រុមហ៊ុន អ្នកអាចផលិតចំណីដោយខ្លួនបាន ដោយទិញគ្រឿង/ជាតុផ្សំសមស្របមួយចំនួនមកផលិត។ នោះពិតជាអាចកាត់បន្ថយថ្លៃដើមចំណីបាន ទោះបីជាយ៉ាងណាក៏ដោយ អ្នកនឹងត្រូវទិញគ្រឿង/ជាតុផ្សំជាច្រើន រក្សាទុក (ដោយផ្នែក) កិននិងលាយវត្ថុជាតុដើមទាំងនេះ ដើម្បីទទួលបានចំណីពេញលេញ។ អ្នកត្រូវដឹងផងដែរថា អ្នកមិនអាចរៀបចំល្បាយវីតាមីន និងសារជាតុរ៉ែសំខាន់ៗបានទេ លុះត្រាតែអ្នកទិញពីក្រុមហ៊ុន។

ដើម្បីកំណត់ថាតើគ្រឿងផ្សំណាមួយដែលត្រូវទិញ មានកម្មវិធី (App) ឥតគិតថ្លៃចំនួនពីរដែលអាចប្រើបាន ដើម្បីផលិតចំណីមានគុណភាពតម្លៃទាបបំផុត ដោយផ្អែកលើចំណីដែលមានក្នុងមូលដ្ឋាន។

### ៤.១.៣. ជម្រើសទី 1៖ ការប្រើរូបមន្តបែងចែកជាតុផ្សំចំណីដោយប្រើ ឧបករណ៍ ភៀសិនស្វែរ (Pearson Square) សាមញ្ញៗ

វាអាចប្រើបាននៅពេលដែលអ្នកមានគ្រឿងផ្សំតែ ២ មុខដូចជា ពោត និង ម្សៅសណ្តែកសៀង ហើយអ្នកចង់ដឹងថាតើត្រូវប្រើគ្រឿងផ្សំនីមួយៗប៉ុន្មាន ដើម្បីទទួលបានកម្រិតប្រូតេអ៊ីនត្រឹមត្រូវនៅក្នុងល្បាយចំណី។ ចំពោះបញ្ហានេះ អ្នកត្រូវដឹងពីតម្រូវការកម្រិតប្រូតេអ៊ីនរបស់មាន់ក្នុងស្រុក (**ប្រហែល ១៦%**) និងកម្រិតប្រូតេអ៊ីនទាំងពោត និង ម្សៅសណ្តែកសៀង ដើម្បីមាន់លូលាស់បានល្អ។ ពោតមានកម្រិតប្រូតេអ៊ីនឆៅ ប្រហែល ៩,៧% នៅអាស៊ី យោងទៅតាម Filipodia (https://www.feedipedia.org/)។ ទោះបីជាយ៉ាងណាក៏ដោយ កម្រិតប្រូតេអ៊ីនឆៅរបស់ម្សៅសណ្តែកសៀងប្រែប្រួល ដោយសារមានប្រភេទសណ្តែកផ្សេងៗគ្នាផងដែរ។ ម្សៅសណ្តែកសៀង ៥០ ប្រភេទមាន ប្រូតេអ៊ីនឆៅ ប្រហែល ៥៥%, ម្សៅសណ្តែកសៀង ៤៨ ប្រភេទ មានប្រូតេអ៊ីឆៅប្រហែល ៥៣%, ម្សៅសណ្តែកសៀង ៤៤-៤៦ ប្រភេទមាន ប្រូតេអ៊ីឆៅប្រហែល ៥០% និងប្រភេទ ម្សៅសណ្តែកសៀង ដែលមាន 'ប្រេងខ្ពស់' មាន ប្រូតេអ៊ីឆៅ ប្រហែល ៤៧% ដូច្នេះវាជាការល្អក្នុងការស្វែងយល់ថាតើ ម្សៅសណ្តែកសៀង មួយណាអាចប្រើបាន។ ដូចនេះ យើងសន្មត់ថា យើងមានប្រភេទម្សៅសណ្តែកសៀងដែលមានប្រូតេអ៊ីនឆៅ ៥០% ហើយសម្រាប់ពោត យើងសន្មត់ថា មានប្រូតេអ៊ីនឆៅ ១០%។

**នៅក្នុងឧបករណ៍ ភៀសិនស្វែរ យើងគណនាដូចខាងក្រោម៖**

សណ្តែកសៀងមានប្រូតេអ៊ីនឆៅ៥០%

សណ្តែកសៀង៦ភាគ *(ភាពខុសគ្នា ១៦ និង ១០)*




ពោតមានប្រូតេអ៊ីនឆៅ ១០%

ពោត៣៤ភាគ *(ភាពខុសគ្នា ១៦ និង ៥០)*

សរុបមកយើងមាន (៦+៣៤=) ៤០ ភាគ។ សមមាត្រនៃ សណ្តែកសៀង មាន ៦ ក្នុងចំណោម ៤០ ដែលត្រូវជា (៦/៤០ * ១០០% = ១៥%)នៃពោត។ ចំណែកពោតមាន ៣៤ ក្នុងចំណោម ៤០ ដែលត្រូវជា (៣៤/៤០ * ១០០% = ៨៥%)។ ដូច្នេះ បើយើងចង់រៀបចំចំណីមួយថង់ទម្ងន់ ៣០គីឡូក្រាម អ្នកត្រូវការ (១៦% នៃ ៣០ គីឡូក្រាម) = ៤,៥ គីឡូក្រាម ម្សៅសណ្តែកសៀង និង (៨៥% នៃ ៣០ គីឡូក្រាម) = ២៥,៥ គីឡូក្រាម ពោត។

ជាលទ្ធផលគឺ ល្បាយ ៣០ គីឡូក្រាមនឹងមានប្រូតេអ៊ីនឆៅ ១៦% តាមតម្រូវការរបស់មាន់។ ទោះជាយ៉ាងណាក៏ដោយ កុំរំពឹងថា នេះជាចំណីដែលមានសមមាត្រសារជាតុចិញ្ចឹមគ្រប់គ្រាន់! ចំណីនេះបំពេញតាមតម្រូវការប្រូតេអ៊ីនឆៅ ប៉ុន្តែមិនទាន់មានតុល្យភាពនៃតម្រូវការសារជាតុចិញ្ចឹមផ្សេងទៀតទាំងអស់ទេ។

#### ៤.១.៤. ជម្រើសទី 2៖ ប្រើរូបមន្តផ្សំចំណីដែលមានក្នុងកម្មវិធីអនឡាញ

មានរូបមន្តផ្សំចំណីក្នុងកម្មវិធីអនឡាញដោយឥតគិតថ្លៃ https://www.feedaccess.com/en.html ដើម្បីផ្តល់នូវរូបមន្តធ្វើឲ្យចំណីមានសារជាតុចិញ្ចឹមពេញលេញប្រកបដោយគុណភាពហើយចំណាយតិចបំផុតដោយប្រើជាតុផ្សំដែលមាននៅក្នុងមូលដ្ឋាន។ ដើម្បីប្រើប្រាស់កម្មវិធី ដំបូងអ្នកត្រូវចូលទៅកាន់គេហទំព័រដែលអ្នកនឹងឃើញប៊ូតុងមួយដើម្បីចូលប្រើកម្មវិធី បន្ទាប់មកអ្នកត្រូវចុះឈ្មោះចូលកម្មវិធី ឬភ្ជាប់ទៅកម្មវិធីនៅពេលអ្នកបានចុះឈ្មោះរួចហើយ។ សៀវភៅណែនាំប្រើប្រាស់រូបមន្តផ្សំចំណីក៏អាចរកបាននៅលើអ៊ីនធឺណិត ( https://appli.feedaccess.com/sos/en/ )។

### ៤.២. ទឹក

ទឹកគឺជាសារជាតិសំខាន់បំផុត ក្នុងអាហារូបត្ថម្ភរបស់មាន់ដែលគេមិនបានយកចិត្តទុកដាក់ដល់។ ទោះបីជាសត្វមាន់មិនអាចផឹកទឹកក្នុងរយៈពេលខ្លីក៏ដោយ ការលូតលាស់របស់វានឹងរងផលប៉ះពាល់ ដូចនេះទឹកស្អាតត្រូវតែមានឲ្យមាន់ផឹកគ្រប់ពេលវេលា។ ដូចបានរៀបរាប់ពីមុនមក ទឹកត្រូវតែស្អាត ប៉ុន្តែស្នូកទឹកក៏ត្រូវស្អាតដែរ ដើម្បីជៀសវាងទឹកកខ្វក់/ពុល ដែលបង្កឡើងពីស្នូកទឹក។ សីតុណ្ហភាពកាន់តែខ្ពស់ មាន់កាន់តែត្រូវការផឹកទឹក ដូច្នេះនៅថ្ងៃក្តៅ មាន់ត្រូវការផឹកទឹកច្រើន។ ប៉ុន្តែនៅពេលថ្ងៃក្តៅខ្លាំង ទឹកនៅក្នុងស្នូកក៏ឡើងកំដៅយ៉ាងលឿនដែរ ហើយនៅពេលដែលទឹកឡើងក្តៅជាង ៣០អង្សាសេ មាន់ផឹកមិនបានច្រើនតាមតម្រូវការរបស់វាទេ។ ដូច្នេះវាមានសារៈសំខាន់ណាស់ក្នុងការផ្តល់ទឹកថ្មី ហើយត្រជាក់ ឲ្យបានច្រើនដងក្នុងមួយថ្ងៃ ហើយត្រូវប្រាកដថាស្នូកទឹកក៏ត្រូវលាងសម្អាតឲ្យបានស្អាត ញឹកញាប់ផងដែរ។

## ៥. ភាពតានតឹង (ស្រ្តេស)ដោយកំដៅ

នៅថ្ងៃដំបូងបន្ទាប់ពីកូនមាន់ញាស់ កូនមាន់ត្រូវការសីតុណ្ហភាពចន្លោះពី ៣២ - ៣៧ អង្សាសេ ប៉ុន្តែសីតុណ្ហភាពនោះ នឹងត្រូវបន្ថយបន្តិចម្តងៗ ក្នុងរយៈពេលពីរ-បីសប្តាហ៍បន្ទាប់មកត្រឹមតែ ១៨ - ២៤ អង្សាសេ ដើម្បីឲ្យការរស់នៅរបស់ពួកវាមានផាសុកភាពល្អ។ ប៉ុន្តែនៅប្រទេសកម្ពុជាមានអាកាសធាតុក្តៅខ្លាំងជាញឹកញាប់ ដែលប៉ះពាល់ដល់ការស៊ីចំណី និងការលូតលាស់របស់មាន់។ លើសពីនេះ វានឹងផ្តល់ភាពតានតឹង ដល់មាន់ ដែលធ្វើឲ្យមាន់ងាយមានបញ្ហាសុខភាព។ វាមិនមែនគ្រាន់តែសីតុណ្ហភាពមួយប៉ុណ្ណោះទេ ប៉ុន្តែសីតុណ្ហភាពខ្ពស់គួបផ្សំ នឹងសំណើមខ្ពស់ ក៏ជាបញ្ហាយ៉ាងពិតប្រាកដ។សំណាងល្អ មាន់អាចស៊ាំនឹងលក្ខខណ្ឌកំដៅបានខ្លះៗ ហើយជាមួយនឹងការគ្រប់គ្រងសមស្រប នោះផលប៉ះពាល់អវិជ្ជមានដោយសារអាកាសធាតុក្តៅអាចនឹងត្រូវបានកាត់បន្ថយ។

## ៥.១. ការធ្វើឲ្យកំដៅខ្លួនមាន់ថយចុះ

ដើម្បីបញ្ចេញកំដៅដែលលើសក្នុងខ្លួន នៅពេលមាន់ឡើងកំដៅដោយសារអាកាសធាតុក្តៅ ពេលនោះមាន់បញ្ចេញកំដៅចេញពីខ្លួនរបស់វា ដោយព្យាយាមស្វែងរកកន្លែងត្រជាក់ ដើម្បីសំងិលខ្លួនធ្វើឲ្យរាងកាយវាចុះត្រជាក់។



ពេលដែលមាន់ក្តៅកាន់តែខ្លាំង មាន់ចាប់ផ្តើមត្រដាងស្លាប ចំពុះមាន់បើកចំហរ ហើយការដកដង្ហើមញាប់ៗ ក៏ក្លាយជាដង្ហក់។ បើមនុស្សយើងវិញពេលក្តៅខ្លាំងចាប់ផ្តើមបែកញើស ដែលញើសនឹងចេញពីស្បែក ហើយរំហួតនេះនាំកំដៅទៅជាមួយស្បែក ហេតុនេះហើយ ទើបធ្វើឲ្យមនុស្សចុះត្រជាក់បាន។ ប៉ុន្តែមាន់មិនអាចបែកញើសបានទេ ដោយសារការដកដង្ហើមញាប់ ទឹកចេញពីសួតត្រូវបានរំហួត ធ្វើឲ្យមានភាពត្រជាក់ដូចគ្នា។ សីតុណ្ហភាពលើសពី ២៥ អង្សារសេ នោះនឹងធ្វើឲ្យមាន់ឆាប់ចុះត្រជាក់លឿន។

## ៥.២. ការកាត់បន្ថយតាពតានតឹង(ស្ត្រេស)ដោយកំដៅ

### ៥.២.១. កាត់បន្ថយសីតុណ្ហភាពដែលប៉ះពាល់ផ្ទាល់

ប្រាកដណាស់ថា កសិករមិនអាចកាត់បន្ថយសីតុណ្ហភាពបរិយាកាសបានទេ ប៉ុន្តែកសិករអាចកែប្រែស្ថានភាពដែលក្តៅក្នុងទ្រុងមកចុះត្រជាក់បានតាមរយៈការរៀបចំទ្រុងឲ្យមានដំបូលពីរជាន់ ការបាញ់ទឹកលើដំបូល និងការដាក់ពិដានអ៊ីហ្សូឡង់ក្នុងទ្រុងដើម្បីជួយទប់កំដៅបានមួយចំនួនធំ។ ការចាំងពន្លឺថ្ងៃផ្ទាល់ចូលក្នុងទ្រុងមាន់ គួរតែជៀសវាង។ ដំបូលសង្ក័សីមានភាពងាយស្រួលក្នុងការជួសជុល ហើយប្រើប្រាស់បានយូរ ប៉ុន្តែវាក៏បញ្ចេញរលកកំដៅខ្លាំងពីព្រះអាទិត្យទៅកាន់មាន់នៅខាងក្នុងទ្រុងផងដែរ ជាពិសេសនៅពេលដែលចន្លោះរវាងដំបូល និងមាន់មានកំរិតទាប។ ដើម្បីអាចជំនះចំណុចនេះបាន កសិករអាចពិចារណាលើការដាក់អ៊ីសូឡង់ឬទ្រនាប់ការពារកំដៅពីដំបូល ឬប្រក់ដំបូលស្បូវ។ ចូរចាំថាដំបូលស្បូវក៏អាចទាក់ទាញពពួកកណ្តុរ និងសត្វស្លាបមករស់នៅផងដែរ ដែលជាពពួកភ្នាក់ងារចំឡងជំងឺដល់មាន់ផងដែរ។



នៅប្រទេសវៀតណាម កសិករបានដាំរុក្ខជាតិដុះវារលើដំបូលទ្រុងមាន់របស់គាត់។ ស្លឹករុក្ខជាតិបៃតង នឹងស្រូបយកកំដៅបានច្រើនពីព្រះអាទិត្យ ធ្វើឲ្យបរិយាកាសក្នុងទ្រុងមាន់ចុះត្រជាក់ល្អសម្រាប់មាន់។ កសិករត្រូវយកចិត្តទុកដាក់បន្ថែម ក្នុងការការពារជំងឺដែលចូលក្នុងទ្រុងមាន់ ព្រោះរុក្ខជាតិទាំងនេះក៏ទាក់ទាញពពួកកណ្តុរ និងបក្សីផ្សេងៗផងដែរ។

### ៥.២.២. ការផ្តល់ចំណីពេលអាកាសធាតុត្រជាក់

អាកាសធាតុត្រជាក់បំផុតគឺពេលព្រឹកព្រលឹម ហើយពេលថ្ងៃក្តៅបំផុត គឺពេលរសៀល។ ទោះបីជាសីតុណ្ហភាពធ្លាក់ចុះបន្តិចនៅពេលរសៀលក៏ដោយ ក៏នៅតែក្តៅ ព្រោះជាធម្មតាសំណើមកើនឡើង ជាពិសេស គឺការរួមបញ្ចូលគ្នានៃសីតុណ្ហភាពខ្ពស់ និងសំណើមដែលធ្វើឲ្យវាក្តៅ។ នៅពេលដែលកូនមាន់កំពុងស៊ីចំណីដើម្បីធ្វើការបំបែករំលាយ ដែលដំណើរការនេះធ្វើឲ្យរាងកាយមានភាពកក់ក្តៅ ដូច្នេះសត្វមាន់ស៊ីចំណីតិចតួចក្នុងអំឡុងពេលអាកាសធាតុក្តៅបែបនេះ។ សូម្បីតែពេលព្រលប់មាន់នៅតែមានអារម្មណ៍ក្តៅ ដោយសារតែសំណើមកើនឡើង ប៉ុន្តែនៅពេលដែលអ្នកបើកភ្លើងនៅម៉ោង ១០ យប់ ហើយទុកវារហូតដល់ថ្ងៃរះ នោះមាន់មានឱកាសច្រើនក្នុងការស៊ីចំណីក្នុងអំឡុងពេលអាកាសធាតុចុះត្រជាក់ពេលយប់។

### ៥.២.៣. ធានាឲ្យមានខ្យល់ចេញចូលត្រឹមត្រូវ

ចរន្តខ្យល់ជុំវិញទ្រុងមាន់នឹងជួយឲ្យមាន់ត្រជាក់ផងដែរ។ អាស្រ័យហេតុនេះ សូមប្រាកដថា ទ្រុងមាន់អាចឲ្យមានខ្យល់ចេញចូលបានល្អ ហើយដាក់មាន់នៅកន្លែងដែលខ្យល់ចេញចូលបានគ្រប់គ្រាន់។ ដំណាំ និងដើមឈើតូចៗ ឬគុម្ពោតព្រៃផ្សេងៗនៅជិតទ្រុង នឹងរារាំងចរន្តខ្យល់ចេញ-ចូល ហើយ វាក៏ជាទាក់ទាញសត្វព្រៃដែលយើងមិនចង់បាន មកជិតទ្រុងមាន់យើងផងដែរ។ កម្រាលទ្រុងមានប្រហោង នឹងរួមចំណែកជំរុញឲ្យមានខ្យល់ចេញចូលបានគ្រប់គ្រាន់ ក្រៅពីនេះជួយកាត់បន្ថយការប្រឡូកប្រឡាក់រវាងមាន់ និងលាមកបានល្អ។



គំនូរព្រាងបង្ហាញពីទ្រុងមាន់ ដែលមានដំបូលចំហរ (មានសំណាញ់លួសការពារសត្វព្រៃចូល)។ គំនូរព្រួញក្រហមបង្ហាញពីចរន្តខ្យល់ក្តៅក្នុងទ្រុងដែលបក់ឡើងលើ រួចបក់ចេញមកក្រៅតាមដំបូលចំហរខាងលើ។ ការបក់ខ្យល់ក្តៅចេញនេះ ត្រូវបានជំនួសដោយខ្យល់ត្រជាក់វិញ ជាគំនូរព្រួញពណ៌ខៀវដែលបក់ចូលមកពីចំហៀងទ្រុងវិញ។ ក្នុងទំរង់នេះគឺមានចរន្តខ្យល់ចេញ ចូលបានល្អ។

### ៥.២.៤. ត្រូវប្រាកដថាកូនមាន់ផឹកទឹកត្រជាក់!

វិធីសាសាស្ត្រដែលល្អបំផុតក្នុងការកាត់បន្ថយភាពតានតឹង(ស្រ្តេស)របស់មាន់ដោយសារកំដៅ គឺត្រូវផ្តល់ទឹកត្រជាក់ឲ្យមាន់ផឹក។ដូចដែលបានរៀបរាប់នៅក្នុងផ្នែកទី៥.១. នៅលក្ខខណ្ឌអាកាសធាតុក្តៅ មធ្យោបាយសំខាន់របស់មាន់ដើម្បីធ្វើឲ្យខ្លួនវាចុះត្រជាក់គឺ ការហួតទឹកចេញពីរាងកាយដោយការដកដង្ហើម។ ដូច្នេះមាន់ត្រូវផឹកទឹកឲ្យបានច្រើន ព្រោះមាន់ត្រូវការទឹកដល់ទៅ៥ដងនៃចំនួនចំណីដែលវាស៊ីឯណោះ។ ប៉ុន្តែក្នុងលក្ខខណ្ឌអាកាសធាតុក្តៅ នោះទឹកក៏ឡើងកម្តៅដែរ ជាទូទៅសីតុណ្ហភាពក្នុងទឹកអាចឡើងខ្ពស់ជាង ៣០

អង្សាសេ។ ជាបញ្ហាគឺថា នៅពេលថ្ងៃដែលមានកម្ដៅក្ដៅខ្លាំង មាន់គួរតែផឹកទឹកឲ្យបានច្រើន ប៉ុន្តែនៅពេលដែលសីតុណ្ហភាពទឹកលើសពី ៣០អង្សាសេ មាន់ផឹកទឹកតែបន្តិចបន្តួចប៉ុណ្ណោះ ហើយពេលដែលសីតុណ្ហភាពទឹកឡើងដល់ ៤៤ អង្សាសេ មាន់នឹងមិនចង់ផឹកទឹកទាល់តែសោះ។

ការផ្ដល់ទឹកត្រជាក់ដល់មាន់ផឹក មិនត្រឹមតែមានសារៈសំខាន់ក្នុងការបញ្ចុះកំដៅដែលលើសនោះទេ ប៉ុន្តែវានឹងធ្វើឲ្យរាងកាយមាន់ត្រជាក់ផងដែរ។



ប្រសិនបើកសិករប្រើធុងទឹកដូចក្នុងរូបភាពនេះ សូមប្រាកដថា វាត្រូវបានដាក់ក្នុងម្លប់ (មិនដូចធុងទឹកក្នុងរូបភាពនេះទេ)។ ដូចគ្នានេះផងដែរ ទុយោទឹកមិនគួរដាក់ហាលថ្ងៃ។ ហេតុនេះ គួរតែធ្វើគម្រប ដំបូល ការពារកំដៅ និងកប់ទុយោនៅក្នុងដី។ ក្នុងរូបភាពនេះ ទឹកផឹកមានកំដៅក្ដៅជាង ៣០ អង្សារសេ។ ដោយសារទឹកក្ដៅ មាន់ផឹកទឹក និងស៊ីចំណីបានតិច មិនសូវលូតលាស់ និងងាយទទួលរងភាពតានតឹង(ស្ត្រេស)ដោយសារកំដៅ។ អ្នកអាចកែលម្អធុងទឹកនេះបាន ដោយការលាបពណ៌សជុំវិញ ដោយសារពណ៌សប្លាតពន្លឺព្រះអាទិត្យទៅវិញ។



វិធីមួយទៀត ដើម្បីធ្វើឲ្យទឹកត្រជាក់ត្រូវបានបង្ហាញនៅក្នុងរូបភាពនេះ។ ធុងទឹកត្រូវបានគ្របដោយបាវសើម។ សំណើមក្នុងបាវនឹងហួតបន្តិចម្ដងៗ ហើយក៏ស្រូបកំដៅពីធុងទឹកបាន ហេតុនេះធ្វើឲ្យទឹកក្នុងធុងចុះត្រជាក់។ ឥទ្ធិពលនៃភាពត្រជាក់ អាស្រ័យទៅលើលំហូរខ្យល់ជុំវិញធុង(កាន់តែច្រើនកាន់តែល្អ)និងសំណើមបរិយាកាស(សំណើមតិចក្នុងខ្យល់ ការហួតកាន់តែតិច ដូច្នេះហើយភាពត្រជាក់កាន់តែច្រើន)។ នៅក្នុងរូបភាពនេះ អ្នកអាចមើលឃើញថាទុយោទឹក មិនមានអ្វីការពារពីកំដៅថ្ងៃទេ (អ៊ីសូឡង់) ដូចនេះ ទឹកត្រជាក់អាចឡើងកំដៅបានតាមរយៈទុយោបង្ហូរទឹក មុនពេលទឹកត្រូវបានផ្ដល់ឱ្យមាន់ផឹក។ ហេតុនេះ គួរតែធ្វើយ៉ាងណាដើម្បីការពារទុយោទឹកពីកំដៅថ្ងៃ។

## ៦. ការភ្ញាស់កូនមាន់

### ៦.១.ការរៀបចំភ្ញាស់កូនមាន់តាមបែបធម្មជាតិ

- ត្រូវតែរៀបចំសំបុកមុនមេមាន់រកពង ចំនួនសំបុកត្រូវឱ្យស្មើគ្នា និងចំនួនមេមាន់ និងដាក់នៅកន្លែងដែលមិនសូវមានពន្លឺ
- សំបុកអាចធ្វើពីកញ្ច្រែង បង្គី...ដោយក្រាលស្លឹកគ្រៃ ឬថ្នាំជក់ ឬស្លឹកសៅម៉ៅព្រៃ... ការពារកុំឱ្យកើតស្រមើល បន្ទាប់មកដាក់ចំបើងពីលើ ធ្វើបែបនេះដើម្បីរក្សាកំដៅស៊ុត និងធ្វើឱ្យស៊ុតញាស់ល្អ។
- រដូវត្រជាក់ ឬភ្លៀង ត្រូវដាក់ចំបើងឱ្យក្រាស់ ដើម្បីរក្សារកំដៅឱ្យបានល្អ នៅពេលរដូវក្តៅដាក់ចំបើងស្តើង ដើម្បីកុំឱ្យក្តៅពេកនាំឱ្យស៊ុតខះ មិនញ៉ាស់។
- ក្នុង១សំបុកដាក់ពងពី១២-២០ពង
- ជួយត្រលប់ ឬបង្វិលស៊ុតឱ្យបានយ៉ាងហោច២ដងទៅ ៨ដង/១ថ្ងៃ



### ៦.២.ការភ្ញាស់កូនមាន់តាមបែបសិប្បនិម្មិត

ទូទៅការភ្ញាស់កូនមាន់តាមបែបសិប្បនិម្មិតមានគោលការណ៍សំខាន់៥យ៉ាង គឺ៖

១. សីតុណ្ហភាព៖សីតុណ្ហភាពមានសារៈសំខាន់សម្រាប់ភ្ញាស់កូនក្នុងស៊ុត ។ សីតុណ្ហភាព សមស្របសម្រាប់ភ្ញាស់គឺ <u>**៣៧.០ ទៅ ៣៧.៥ អង្សាសេ។**</u>

២. សំណើម៖អាយុស៊ុតពី **១ ទៅ ១៨ថ្ងៃ** ត្រូវការសំណើមពី **៥៥% ទៅ ៦៥ %** ហើយពេលស៊ុតមានអាយុពី **១៩ថ្ងៃ ទៅ ២១ថ្ងៃ** ត្រូវបង្កើនសំណើមពី **៦០%ទៅ ៧៥%** ។

៣. ការបង្វិលស៊ុត៖ស៊ុតដែលបានបង្វិលត្រឹមត្រូវធ្វើឱ្យជាតិលឿងរបស់ស៊ុតនៅចំកណ្តាល ហើយកូនមាន់បង្កកំណើតបានល្អ បង្វិលរៀងរាល់ **១ទៅ ២ម៉ោងម្តង**( ដោយម៉ាស៊ីនស្វ័យប្រវត្ត) ។ ***ចំណាំ៖*** យើងធ្វើការបង្វិលស៊ុតនៅអាយុពី **១ ទៅ ១៨ថ្ងៃ** ហើយអាយុពី**១៩ ថ្ងៃ ទៅ ២១** ថ្ងៃមិនចាំបាច់បង្វិលទៀតទេ ។

៤. ចរន្តខ្យល់ក្នុងទូរភ្ញាស់៖ អំប្រីយ៉ូស៊ុត ត្រូវការស្រូបយកអុកស៊ីសែន ហើយបញ្ចេញមកវិញនូវឧស្ម័នកាបូនិច ។ ចរន្តខ្យល់ចេញចូលជួយឱ្យមានលំនឹងអុកស៊ីសែនក្នុងទូរ និងការស្រូបរបស់ស៊ុតជាពិសេស ស៊ុតភ្ញាស់មានអាយុពី **១៥ ទៅ ១៨ថ្ងៃ** ។

៥. អនាម័យទូរះស៊ុតងាយទទួលរងនៅជំងឺផ្សេងៗ ដូចច្នេះទូរភ្ញាស់ត្រូវតែស្អាត អនាម័យ និង បរិស្ថានល្អ ។







## ៧. សុខភាព និងការចាក់ថ្នាំវ៉ាក់សាំង

យើងត្រូវធ្វើវ៉ាក់សាំងការពារជំងឺមាន់ ៣ ប្រភេទ គឺ៖

១. វ៉ាក់សាំងការពារជំងឺ ញ៉ូវកាស (ជំងឺដង្គោកាច់)។ ជំងឺនេះ ច្រើនផ្ទុះឡើងនៅចន្លោះខែកុម្ភៈ ដល់ចុងខែឧសភា (រដូវប្រាំង)

២. វ៉ាក់សាំងការពារជំងឺ អុត (ដុះដុំពកនៅលើក្បាល ឬនៅកន្លែងដែលគ្មានរោម)។ វាអាចកើតមានគ្រប់ពេលវេលា

៣. វ៉ាក់សាំងការពារជំងឺអាសន្នរោគ។ ជំងឺអាសន្នរោគច្រើនផ្ទុះនៅខែមិថុនា ដល់ខែធ្នូ (រដូវវស្សា)។

ជំងឺមាន់ភាគច្រើន ជាជំងឺកាចសាហាវ មានការរាលដាលខ្លាំង ហើយបណ្តាលឲ្យមាន់ងាប់ច្រើន និងពិបាកព្យាបាល (ការព្យាបាល់មិនសូវមានប្រសិទ្ធភាពទេ) ដូច្នេះវិធីដែលល្អប្រសើរបំផុតគឺ ចាក់វ៉ាក់សាំងការពារជាមុន។




ចំណាំ៖ ប្រសិនបើទុកមាន់ធ្វើពូជ វ៉ាក់សាំងអាយធូ (I2) និង អាសន្នរោគ ត្រូវធ្វើរំលឹករៀងរាល់ ៦ ខែម្តង ទំលាក់សត្វល្អិត (ព្រូន) រំលឹកសារថ្មី រៀងរាល់ ៣ខែ ម្តង

តើកត្តាអ្វីខ្លះដែលធ្វើឲ្យការចាក់វ៉ាក់សាំងមានប្រសិទ្ធិភាព?

- មុនធ្វើវ៉ាក់សាំង យើងត្រូវ៖
  - ក្រុងមាន់ដែលមានសុខភាពល្អទុកដោយឡែកពីមាន់មានសុខភាពមិនល្អ
  - ធ្វើអ្វីមួយសំគាល់លើមាន់ដែលត្រូវធ្វើវ៉ាក់សាំងលើកទី1
  - មានធុងទឹកកក+ទឹកកកសំរាប់ដាក់វ៉ាក់សាំង សម្ភារៈ និងឧបករណ៍ ...
  - ទិញវ៉ាក់សាំងដែលមានសុពលភាព ដបវ៉ាក់សាំងនៅមានទ្រង់ទ្រាយល្អ។

- ពេលធ្វើវ៉ាក់សាំង យើងត្រូវ៖
  - វ៉ាក់សាំងត្រូវបានរក្សាទុកដាក់បានល្អ (ត្រជាក់)
  - ធ្វើវ៉ាក់សាំងមាន់ពេលត្រជាក់ (ព្រឹក ឬល្ងាច មិនឲ្យប៉ះពន្លឺព្រះអាទិត្យ)
  - ធ្វើវ៉ាក់សាំងតែលើមាន់មានសុខភាពល្អប៉ុណ្ណោះ
  - យកក្រណាត់ត្រជាក់រុំដបវ៉ាក់សាំងទើបចាប់កាន់/ ឬយកដៃជ្រលក់នឹងទឹកកកសិន
  - វ៉ាក់សាំងត្រូវធ្វើទៅតាមប្រភេទ (ចាក់ដឹងចាក់ បន្តក់ដឹងបន្តក់ ដួសស្លាបដឹងដួសស្លាប)
  - ឧបករណ៍ស្អាត និងមានអនាម័យ
  - មាន់១ក្បាលធ្វើវ៉ាក់សាំងតែ១ដងក្នុង១ពេលប៉ុណ្ណោះ (ចាក់ ២ ដងអាចងាប់មាន់) ។

- ក្រោយពេលធ្វើវ៉ាក់សាំង៖
  - ដាក់ទឹកឲ្យមាន់ផឹកឲ្យបានគ្រប់គ្រាន់ និងផ្តល់ចំណីដែលមានប្រូតេអ៊ីន និងវីតាមីនគ្រប់គ្រាន់
  - ក្រុងមាន់ដែលធ្វើវ៉ាក់សាំងរួច ១-៣ថ្ងៃ
  - បាចកំបោរកន្លែងធ្វើវ៉ាក់សាំង និងពីក្រោមទ្រុងដែលរក្សាទុកមាន់ទើបធ្វើវ៉ាក់សាំង
  - កាកសំណល់វ៉ាក់សាំងត្រូវដុតចោល ល្អជាងកប់ចោល
  - ធ្វើកំណត់ត្រាថ្ងៃដែលបានធ្វើវ៉ាក់សាំង និងថ្ងៃដែលត្រូវធ្វើរំលឹកវ៉ាក់សាំងលើកទី២ និងទី៣
  - តាមដានសុខភាពមាន់ (បំបែកមាន់ឈឺចេញបើមាន)។

# ផ្នែកទី២ ចំណេះដឹងហិរញ្ញវត្ថុ

## ១. សេចក្តីណែនាំពីចំណេះដឹងហិរញ្ញវត្ថុ

### ១.១. និយមន័យចំណេះដឹងហិរញ្ញវត្ថុ

ចំណេះដឹងផ្នែកហិរញ្ញវត្ថុ គឺជាសមត្ថភាពក្នុងការយល់ និងប្រើប្រាស់ជំនាញហិរញ្ញវត្ថុផ្សេងៗប្រកបដោយប្រសិទ្ធភាព រួមទាំងថវិកា ការវិនិយោគ និងការគ្រប់គ្រងលុយ។

### ១.២. សារៈសំខាន់នៃចំណេះដឹងហិរញ្ញវត្ថុ

ចំណេះដឹងនេះមានសារៈសំខាន់សម្រាប់ការសម្រេចចិត្ត ការគ្រប់គ្រងហានិភ័យ និងការធានានូវនិរន្តរភាពយូរអង្វែងក្នុងការធ្វើកសិដ្ឋាន។

**ការរៀបចំថវិកា៖** គឺការបង្កើតផែនការ សម្រាប់គ្រប់គ្រងចំណូល និង ចំណាយ។
**ការកត់ត្រា៖** ការកត់ត្រា និងការរក្សាប្រតិបត្តិការហិរញ្ញវត្ថុ (លុយ) អោយបានត្រឹមត្រូវអាចអោយគាត់ដឹងរបៀបនៃការរៀបចំថវិកា និងការសម្រេចចិត្តក្នុងការវិនិយោគបន្ត។
**ការវិភាគហិរញ្ញវត្ថុ៖**គឺជាការវាយតម្លៃទិន្នន័យហិរញ្ញវត្ថុដែលបានកត់ត្រា ដើម្បីជាមូលដ្ឋានក្នុងការសម្រេចចិត្ត។
**ការគ្រប់គ្រងហានិភ័យ៖** គឺជាការកំណត់អត្តសញ្ញាណហានិភ័យ និងកំណត់វិធានការគ្រប់គ្រងដើម្បីកាត់បន្ថយហានិភ័យហិរញ្ញវត្ថុ។
**ផែនការវិនិយោគ៖** ការចំណាយ/ដាក់ធនធានសម្រាប់រក្សា និងបង្កើនការរីកចម្រើនរបស់កសិដ្ឋាន និងទទួលបាននូវប្រាក់ចំណេញត្រឡប់មកវិញ។

## ២. ការកត់ត្រាចំណូល ចំណាយសម្រាប់កសិករ

**កំណត់ត្រាហិរញ្ញវត្ថុ៖** រួមបញ្ចូលកំណត់ត្រាចំណូល និងចំណាយ របាយការណ៍ធនាគារ ឯកសារកម្ចី និងរបាយការណ៍បង់ពន្ធ(បើមាន)។ កំណត់ត្រាទាំងនេះជួយក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ និងវាយតម្លៃប្រាក់ចំណេញរបស់កសិដ្ឋាន។

**កំណត់ត្រាផលិតកម្ម៖** រួមបញ្ចូលព័ត៌មានលម្អិតនៃទិន្នផលមាន់ និងការប្រើប្រាស់ធាតុចូល(ឧទាហរណ៍ សម្ភារៈធ្វើទ្រុង ពូជមាន់ ចំណី វ៉ាក់សាំង ម៉ាស៊ីនវាយចំណី ទែម៉ូម៉ែត្រវាស់កំដៅ)។កំណត់ត្រាទាំងនេះជួយ ក្នុងការវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តកសិដ្ឋាន និងការរៀបចំផែនការសម្រាប់ផលិតកម្មនៅថ្ងៃខាងមុខ។

**កំណត់ត្រាសារពើភណ្ឌ៖**រួមបញ្ចូលព័ត៌មានអំពីបរិមាណ និងតម្លៃនៃទ្រព្យសម្បត្តិកសិដ្ឋាន ដូចជាឧបករណ៍ ម៉ាស៊ីនកិនចំណី និងផលិតផលដែលរក្សាទុក។ កំណត់ត្រាទាំងនេះមានសារៈសំខាន់សម្រាប់ការគ្រប់គ្រង ធនធានកសិដ្ឋាន និងការធ្វើផែនការធនធានឱ្យប្រសើរឡើង។

**និយមន័យកំណត់ត្រាហិរញ្ញវត្ថុ** ៖ ការរក្សាទុកនូវកំណត់ត្រាហិរញ្ញវត្ថុ និងជាដំណើរការនៃការកត់ត្រាត្រឹមត្រូវ នៃបច្ចុប្បន្នភាពប្រតិបត្តិការហិរញ្ញវត្ថុ និងសកម្មភាពដែលពាក់ព័ន្ធផ្សេងៗក្នុងកសិដ្ឋាន។

**សារៈសំខាន់នៃការកត់ត្រាហិរញ្ញវត្ថុ៖** មានសារៈសំខាន់ក្នុងការតាមដានការអនុវត្តក្នុងកសិដ្ឋាន ការធ្វើសេចក្តីសម្រេចចិត្តដែលមានព័ត៌មាន និងជានាការអនុលោមតាមតម្រូវការផ្នែកច្បាប់ និងហិរញ្ញវត្ថុ។

### ២.១. ប្រភេទនៃកំណត់ត្រាដែលត្រូវរក្សាទុក

ក. **កំណត់ត្រាហិរញ្ញវត្ថុ៖** កត់ត្រាចំណូល ចំណាយ ទ្រព្យសកម្ម បំណុល និងលំហូរសាច់ប្រាក់។
ខ. **កំណត់ត្រាផលិតកម្ម៖ កត់ត្រាទិន្នផលមាន់ និងការប្រើប្រាស់ជាតុចូលក្នុកសិដ្ឋានមាន់។**
គ. **បញ្ជីសារពើភណ្ឌ៖** រក្សាទុកម៉ាស៊ីនកិនចំណី ទ្រុង ចំណី និងឧបករណ៍/សម្ភារៈក្នុងកសិដ្ឋាន ។

### ២.២. អត្ថប្រយោជន៍នៃការរក្សាកំណត់ត្រាប្រកបដោយប្រសិទ្ធភាព

គ្រប់គ្រងហិរញ្ញវត្ថុរបស់កសិដ្ឋានមួយឲ្យមានប្រសិទ្ធិភាព កសិករត្រូវធ្វើការកត់ត្រាចំណូល-ចំណាយឲ្យបានទៀងទាត់ និងរក្សាកំណត់ត្រាទាំងនេះអោយបានត្រឹមត្រូវ ព្រោះវាផ្តល់ផលប្រយោជន៍មួយចំនួនដូចជា៖

- ផ្តល់នូវទិដ្ឋភាពដ៏ច្បាស់លាស់អំពីស្ថានភាពហិរញ្ញវត្ថុរបស់កសិដ្ឋាន
- ជំនួយក្នុងការរៀបចំផែនការថវិកា និងហិរញ្ញវត្ថុ
- ជួយកំណត់តំបន់សម្រាប់ការកែលម្អ និងឱកាសសន្សំការចំណាយ។

## ៣. ការរៀបចំថវិកាសម្រាប់កសិដ្ឋាន និងគ្រួសារ

### ៣.១. សារៈសំខាន់នៃការគ្រោងថវិកា៖

- ជួយគ្រប់គ្រងចំណូល និងចំណាយ
- ជួយក្នុងការធ្វើផែនការសម្រាប់តម្រូវការហិរញ្ញវត្ថុនាពេលអនាគត
- ដំណើរការក្នុងការធ្វើការសម្រេចចិត្តកាន់តែប្រសើរ
- ផ្តល់រូបភាពច្បាស់លាស់ពីស្ថានភាពហិរញ្ញវត្ថុ
- ជួយក្នុងការកំណត់គោលដៅហិរញ្ញវត្ថុ និងតាមដានវឌ្ឍនភាព(ភាពរីកចម្រើន)

### ៣.២. ប្រភេទថវិកា

ក្នុងការគ្រប់គ្រងថវិកាឲ្យបានល្អ កសិករគួរបែងចែកថវិការបស់ខ្លួជាពីប្រភេទផ្សេងៗគឺ៖

- ថវិកាសម្រាប់កសិដ្ឋាន៖ ផែនការចំណូល ចំណាយដែលទាក់ទងនឹងកសិដ្ឋាន
- ថវិកាគ្រួសារ៖ ផែនការចំណូល ចំណាយដែលទាក់ទងនឹងគ្រួសា

| ប្រភេទថវិកា | ការពិពណ៌នា |
|---|---|
| ថវិកាសម្រាប់កសិដ្ឋាន | គឺជាផែនការថវិកាដែលទាក់ទងទៅនឹងចំណូល ចំណាយរបស់កសិដ្ឋាន |
| ថវិកាគ្រួសារ | គឺជាផែនការថវិកាដែលទាក់ទងទៅនឹងចំណូល ចំណាយរបស់គ្រួសារ |

### ៣.៣. ការរៀបចំថវិកាសម្រាប់កសិដ្ឋាន និង គ្រួសារ

- ចែកគំរូទម្រង់ថវិកាដល់អ្នកចូលរួម
- បង្ហាញពីរបៀបបំពេញប្រភេទថវិកានីមួយៗដោយប្រើទម្រង់គម្រូ
- ណែនាំអ្នកចូលរួមតាមរយៈសកម្មភាពដោយដៃដែលពួកគេបង្កើតថវិកាសាមញ្ញសម្រាប់កសិដ្ឋាន និង គ្រួសាររបស់ពួកគេ

## ក. គំរូថវិកាសម្រាប់កសិដ្ឋានចិញ្ចឹមមាន់សាច់

| ប្រភេទ | ថវិការវគ្គមុន | ថវិកាប៉ាន់ស្មាន | ជាក់ស្តែង | ភាពខុសគ្នា |
|---|---|---|---|---|
| **ចំណូល** | | | | |
| លក់មាន់សាច់ | | | | |
| លក់លាមកមាន់ | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| ចំណូលផ្សេងៗ | | | | |
| **ចំណូលសរុប** | | | | |
| **ចំណាយ** | | | | |
| ទិញកូនមាន់ | | | | |
| ទិញ/ចាក់វ៉ាក់សាំងមាន់ | | | | |
| ទិញចំណីក្រុមហ៊ុន/ផ្សារ | | | | |
| ទិញកន្ទុក | | | | |
| ចុងអង្ករ | | | | |
| ត្រកួន/បន្លែ | | | | |
| ថ្នាំព្យាបាលមាន់ | | | | |
| ទិញស្នូកទឹក/ចំណី | | | | |
| ធ្វើទ្រុង | | | | |
| ម៉ាស៊ីនវាយចំណី | | | | |
| ទែម៉ូម៉ែត្រ | | | | |
| | | | | |
| | | | | |
| | | | | |
| ការចំណាយផ្សេងៗ | | | | |
| **សរុបចំណាយ** | | | | |
| **ចំណេញ/ខាត** | | | | |

## ខ. គំរូថវិកាសម្រាប់គ្រួសារ

| ប្រភេទ | ថវិកាឆ្នាំមុន | ថវិកាប៉ាន់ស្មាន | ជាក់ស្តែង | ភាពខុសគ្នា |
|---|---|---|---|---|
| **ចំណូល** | | | | |
| ប្រាក់ខែ | | | | |
| ការងារក្រៅពីការចិញ្ចឹមមាន់ | | | | |
| លុយគេផ្ញើរអោយ | | | | |
| | | | | |
| | | | | |
| | | | | |
| ចំណូលផ្សេងៗ | | | | |
| **សរុបចំណូល** | | | | |
| **ចំណាយ** | | | | |
| អាហារ | | | | |
| សម្ភារៈ | | | | |
| កាដឹកជញ្ជូន | | | | |
| ចំណាយលើការព្យាបាលសុខភាព | | | | |
| ការអប់រំ | | | | |
| សម្លៀកបំពាក់ | | | | |
| ជួលផ្ទុលនិងថៃរទាំ | | | | |
| កំសាន្ត | | | | |
| សន្សំ | | | | |
| ចំណាយការងារសង្គម | | | | |
| | | | | |
| | | | | |
| | | | | |
| ចំណាយផ្សេងៗ | | | | |
| **សរុបចំណាយ** | | | | |
| **សន្សំ/ ចំណាយលើសចំណូល** | | | | |

## ៤. ការវិភាគហិរញ្ញវត្ថុសម្រាប់ធ្វើការសម្រេចចិត្ត

**និយមន័យ៖** ការវិភាគហិរញ្ញវត្ថុគឺជាដំណើរការនៃការវាយតម្លៃទិន្នន័យហិរញ្ញវត្ថុ ដើម្បីធ្វើការសម្រេចចិត្តក្នុងការគ្រប់គ្រង និងពង្រីកកសិដ្ឋាន។

**គោលបំណង៖** ការវិភាគហិរញ្ញវត្ថុនេះមានគោលបំណងជួយកសិករអោយបានយល់ដឹងពីស្ថានភាពហិរញ្ញវត្ថុកសិដ្ឋានរបស់ពួកគាត់ ដើម្បីកំណត់បាននូវចំណុចដែលត្រូវកែលម្អ និងរៀបចំផែនការសម្រាប់អភិវឌ្ឍន៍កសិដ្ឋានទៅអនាគត។

**ហេតុអ្វីបានជាយើងចាំបាច់ធ្វើការវិភាគហិរញ្ញវត្ថុសម្រាប់កសិដ្ឋានរបស់អ្នក?**

ដើម្បីអោយកសិករគ្រប់គ្រងហិរញ្ញវត្ថុកសិដ្ឋានរបស់ខ្លួនបានរឹងមាំ កសិករចាំបាច់ត្រូវធ្វើការវិភាគហិរញ្ញវត្ថុលើកកសិដ្ឋានរបស់ខ្លួនដូចជា៖

- **ការវាយតម្លៃប្រាក់ចំណេញ៖** ជួយអោយកសិករវាយតម្លៃប្រាក់ចំណេញនៃប្រតិបត្តិការរបស់ពួកគេ។
- **ការធ្វើសេចក្តីសម្រេចចិត្ត៖** ជួយឱ្យកសិករធ្វើការសម្រេចចិត្តកាន់តែប្រសើរឡើងទាក់ទងនឹងការវិនិយោគ ការចំណាយនិងតម្លៃ
- **ការគ្រប់គ្រងហានិភ័យ៖** ជួយអោយកសិករអាចគ្រប់គ្រង និងកាត់បន្ថយហានិភ័យ និងការធ្វើ ផែនការរយៈពេលវែង។
- **ផលជះនៃជីវិតពិតរបស់កសិករ៖** បង្ហាញជាឧទាហរណ៍ពីវិធី ថាតើការវិភាគហិរញ្ញវត្ថុបានជួយអ្វីខ្លះដល់កសិករ ដើម្បីឱ្យទទួលបានជោគជ័យ។

### ៤.១ ទិដ្ឋភាពទូទៅនៃគំនិតហិរញ្ញវត្ថុ

កសិករចាំបាច់ត្រូវយល់ដឹងពីទិដ្ឋភាពទូទៅនៃគំនិតហិរញ្ញវត្ថុ ដើម្បីធ្វើការវិភាគហិរញ្ញវត្ថុអោយ បានត្រឹមត្រូវ និងច្បាស់លាស់សម្រាប់គ្រប់គ្រងហិរញ្ញវត្ថុកសិដ្ឋានរបស់ខ្លួនអោយបានជោគជ័យ។ ទិដ្ឋភាព ទាំងនោះរួមមាន៖

- **ចំណូល៖** ប្រាក់ចំណូលសរុបដែលបានមកពីការលក់ផលិតផលពីកសិដ្ឋាន។
- **ការចំណាយ៖** ប្រាក់ចំណាយប្រតិបត្តិការសម្រាប់កសិដ្ឋាន រួមមាន (ពូជមាន់, ចំណី, ទ្រុង,វ៉ាក់សាំង, ថ្នាំវីតាមីន, ចាក់ដី, ពលកម្ម និងសម្ភារៈ ...)។

  ចំណាយមានពីរប្រភេទ គឺ ចំណាយថេរ និងចំណាយអថេរ

  - ចំណាយថេរ៖ គឺជាការចំណាយទាំងឡាយណាដែលមិនប្រែប្រួលនៅពេលដែលការលក់ ឬបរិមាណផលិតកម្មកើនឡើង ឬថយចុះ។ ១. ចំណាយសាងសង់ទ្រុងមាន់ ស្នូកទឹក/ចំណី។

- ចំណាយអថេរ៖ គឺជាការចំណាយទាំងឡាយណាដែលប្រែប្រួលដោយផ្អែកលើចំនួនដែលកសិដ្ឋាន ផលិត និងលក់ ដូចជាកម្លាំងពលកម្ម ថ្លៃប្រើប្រាស់ កម្រៃជើងសារ និងវត្ថុធាតុដើម។ ការចំណាយថេរជាធម្មតាមិនអាស្រ័យលើសកម្មភាពអាជីវកម្មជាក់លាក់របស់ក្រុមហ៊ុន។ ចំណាយអថេរកើនឡើង នៅពេលដែលផលិតកម្មកើនឡើង និងធ្លាក់ចុះ។

– **ប្រាក់ចំណេញសុទ្ធ**៖ប្រាក់ដែលនៅសល់បន្ទាប់ពីការចំណាយទាំងអស់ត្រូវបានដកចេញពីចំណូលសរុប។

| |
|---|
| **ប្រាក់ចំណេញសុទ្ធ = ចំណូលសរុប - ចំណាយសរុប** |

ចំណាយសរុបរួមមាន ចំណាយផលិតកម្ម ចំណាយការប្រាក់ ចំណាយចាក់ដី ចំណាយបង់ពន្ធ ...

– **ភាគរយប្រាក់ចំណេញ**៖ គឺជាភាគរយនៃប្រាក់ចំណូលដែលនៅសល់ បន្ទាប់ពីកាត់ចំណាយទាំងអស់ចេញ។

ភាគរយប្រាក់ចំណេញ(%) = ប្រាក់ចំណេញសុទ្ធ / ប្រាក់ចំណូលសរុប X ១០០

ឬ

= (ប្រាក់ចំណូលសរុប-ប្រាក់ចំណាយសរុប) / ប្រាក់ចំណូលសរុប X ១០០

**ឧទាហរណ៍**៖ លោកស្រី គឹម ឆេង ជាកសិកចិញ្ចឹមមាន់សាច់ចំនួន១០០ក្បាល។ គាត់ចំណាយលើផលិតកម្មចិញ្ចឹមមាន់សាច់សរុបចំនួន១.៤៥៧.០០០រៀល ហើយគាត់ទទួលបានចំណូលពីការលក់មាន់សាច់និងអាច់មាន់សរុបចំនួន ២.៣៤០.០០០រៀល។ ដូច្នេះ ប្រាក់ចំណេញសុទ្ធ និងភាគរយប្រាក់ចំណេញ ក្នុង ១វគ្គផលិតកម្មមាន់សាច់គឺ៖

– **ប្រាក់ចំណេញសុទ្ធ = ២. ៣៤០.០០០៛ — ១.៤៥៧.០០០៛ = ៨៨៣.០០០៛**

– **ភាគរយប្រាក់ចំណេញ** = $\frac{\text{២.៣៤០.០០០៛ — ១.៤៥៧.០០០៛}}{\text{២.៣៤០.០០០៛}}$ X ១០០ = ៣៨%

– **ភាគរយប្រាក់ចំណេញ**: ភាគរយនៃប្រាក់ចំណូលដែលនៅសល់បន្ទាប់ពីការចំណាយទាំងអស់ត្រូវបានកាត់ចេញ ៣៨%។ ពោលគឺ គាត់ចំណាយ១០០ រៀល បានចំណេញ ៣៨ រៀល។

– **ផលទទួលបានត្រឡប់ពីការវិនិយោគ**៖ វាស់ផលចំណេញ ឬប្រាក់ចំណេញនៃការវិនិយោគ

– **លំហូរសាច់ប្រាក់**៖ ការតាមដានលំហូរចូល និងលំហូរចេញនៃសាច់ប្រាក់ក្នុងប្រតិបត្តិការកសិដ្ឋាន។

## ៥. ការគ្រប់គ្រងហានិភ័យ និងផែនការអភិវឌ្ឍន៍

កសិករដែលធ្វើការចិញ្ចឹមមាន់ តែងតែជួបបញ្ហាជាច្រើនដែលធ្វើឲ្យអាជីវកម្មរបស់គាត់ទទួលការខាតបង់ ឬបរាជ័យ។ នេះបណ្តាលមក ពីកត្តាហានិភ័យ ដែលកសិករមិនបានគិតទុក ឬព្យាករណ៍ទុកជាមុន។ នៅក្នុងការធ្វើអាជីវកម្មចិញ្ចឹមមាន់ កសិករតែងជួបហានិភ័យមួយចំនួនដូចខាងក្រោម៖

- **ហានិភ័យទីផ្សារ៖** គឺភាពមិនច្បាស់លាស់ទាក់ទងនឹងតម្លៃ តម្រូវការ និងលក្ខខណ្ឌទីផ្សារ (មិនមានកុងត្រា ទិញលក់មិនច្បាស់លាស់ជាមួយដៃគូ មានដៃគូប្រកួតប្រជែងច្រើន)។

- **ហានិភ័យផលិតកម្ម៖** គឺជាបញ្ហាប្រឈមទាក់ទងនឹងផលិតកម្មមាន់ (ខ្វះបច្ចេកទេសចិញ្ចឹម គ្រោះធម្មជាតិ ជំងឺ កង្វះវីតាមីន/ប្រូតេអ៊ីន វិធានការការពារ ........) ។

- **ហានិភ័យហិរញ្ញវត្ថុ៖** គឺជាហានិភ័យទាក់ទងនឹងការគ្រប់គ្រងហិរញ្ញវត្ថុ ឥណទាន(កម្ចី) និងលំហូរសាច់ប្រាក់ (មិនមានទុនបម្រុងទុក អត្រាការប្រាក់ខ្ពស់ បំណុលច្រើន ប្រភពចំណូលទាប)។

- **ហានិភ័យផ្នែកច្បាប់ និងបទប្បញ្ញត្តិ៖** គឺជាការអនុលោមតាមច្បាប់ បទប្បញ្ញត្តិ និងកាតព្វកិច្ចកិច្ចសន្យា។

- **ហានិភ័យផ្នែកធនធានមនុស្ស៖** គឺទាក់ទងនឹងកម្លាំងពលកម្ម សុខភាព និងសុវត្ថិភាពផ្ទាល់ខ្លួន។

- **ហានិភ័យបរិស្ថាន៖** ទាក់ទងទៅនឹងឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុដូចជា ទឹកជំនន់ គ្រោះរាំងស្ងួត ខ្យល់កន្ត្រាក់ ជំងឺ...។

## ៦. ការអនុវត្តចំណេះដឹងហិរញ្ញវត្ថុសម្រាប់ភាពជោគជ័យនៃកសិដ្ឋាន

### ៦.១ ទម្រង់សៀវភៅកត់ត្រាសាច់ប្រាក់

**ទម្រង់សៀវភៅកត់ត្រាសាច់ប្រាក់**

| កាលបរិច្ឆេទ | បរិយាយ | ចំណូល (ខ្មែររៀល) | ចំណាយ (ខ្មែររៀល) | តុល្យភាព (ខ្មែររៀល) |
| --- | --- | --- | --- | --- |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |

## ៦.២ ទម្រង់កត់ត្រារបាយការណ៍ ចំណូល-ចំណាយ សម្រាប់ផលិតកម្មមាន់

### តារាងកត់ត្រារបាយការណ៍ ចំណូល-ចំណាយ សម្រាប់ផលិតកម្មមាន់

| ល.រ | បរិយាយ | ថវិកា (រៀល) |
|---|---|---|
| I | **ការកត់ត្រាចំណូល** | |
| | ចំណូលពីការលក់មាន់សាច់ | |
| | ចំណូលពីការលក់អាចម៍មាន់ | |
| | | |
| | **សរុបចំណូល** | |
| II | **ការកត់ត្រាចំណាយ** | |
| ២.១ | **ចំណាយប្រតិបត្តិការក្នុងផលិកម្មមាន់** | |
| | ដឹកជញ្ជូន | |
| | | |
| | ផ្សេងៗ.................... | |
| | **សរុបចំណាយប្រតិបត្តិការ** | |
| ២.២ | **ចំណាយទិញសំភារៈ និងឧបករណ៍ប្រើប្រាស់៖** | |
| | សម្ភារៈសម្រាប់សាងសង់ទ្រុង | |
| | ម៉ាស៊ីនកិនចំណី | |
| | ទុយោបូមទឹក | |
| | ទែម៉ូម៉ែត្រវាស់កំដៅ | |
| | ស្បែកជើងពាក់ចូលកសិដ្ឋាន | |
| | ធុងបាញ់ថ្នាំ | |
| | ផ្សេងៗ .............................. | |
| | **សរុបចំណាយទិញសំភារៈ និងឧបករណ៍** | |
| ២.៣ | **ចំណាយការប្រាក់, រំលោះ និងផ្សេងៗ** | |
| | ការប្រាក់ត្រូវបង់ប្រចាំខែ | |
| | ការធ្វើទីផ្សារលក់ផលិតផលមាន់ | |
| | រំលោះ (ម៉ាស៊ីនកិនចំណី, ទ្រុង, ធុងបាញ់ថ្នាំ, ទែម៉ូម៉ែត្រ,ស្បែព័ទ្ធ,ស្នូកទឹក, ចំណី... | |
| | ផ្សេងៗ.............. | |
| | **សរុបចំណាយ** | |
| | **ចំណាយសរុប (២.១+ ២.២ + ២.៣)** | |
| III | **ចំណេញសុទ្ធ** | |
| | **ចំណេញសុទ្ធ = ចំណូលសរុប - ចំណាយសរុប** | |

## ៦.៣ ទម្រង់គណនាភាគរយ (%) ប្រាក់ចំណេញ

**តារាងគណនាភាគរយ (%) ប្រាក់ចំណេញ**

| **ពណ៌នា** | **ចំនួន (ខ្មែររៀល)** |
|---|---|
| **ចំណូលសរុប** | |
| ចំណាយថេរ ឬចំណាយប្រតិបត្តិការ | |
| ចំណាយអថេរ ឬចំណាយទិញសំភារៈនិងឧបករណ៍ ការប្រាក់ ការជួលរំលោះ | |
| **ចំណេញសុទ្ធ = ចំណូលសរុប - (ចំណាយថេរ + ចំណាយអថេរ)** | |
| | |
| **ភាគរយប្រាក់ចំណេញ (%) = (ចំណេញសុទ្ធ/ចំណូលសរុប) x 100** | |

## ៦.៨ គម្រូកត់ត្រាប្រតិបត្តិការ ក្នុងកសិដ្ឋានចិញ្ចឹមមាន់

### តារាងកត់ត្រាប្រតិបត្តិការក្នុងកសិដ្ឋានចិញ្ចឹមមាន់

| ប្រតិបត្តិការលក់ | ប្រតិបត្តិការទិញ | ប្រតិបត្តិការចំណាយ | ប្រតិបត្តិការផ្សេងៗ |
| --- | --- | --- | --- |
| ការលក់មាន់៖ | ពូជ៖ | កម្លាំងពលកម្ម៖ | ការសងប្រាក់កម្ចី៖ |
| កាលបរិច្ឆេទ៖ | កាលបរិច្ឆេទ៖ | កាលបរិច្ឆេទ៖ | កាលបរិច្ឆេទ៖ |
| ការពិពណ៌នា៖ | ការពិពណ៌នា៖ | ការពិពណ៌នា៖ | ការពិពណ៌នា៖ |
| ចំនួន៖ | ចំនួន៖ | ចំនួន៖ | ចំនួន៖ |
| ការលក់លាមកមាន់៖ | ចំណីមាន់៖ | ការថែទាំឬជួសជុលសម្ភារៈចិញ្ចឹម៖ | បុព្វលាភធានារ៉ាប់រង៖ |
| កាលបរិច្ឆេទ៖ | កាលបរិច្ឆេទ៖ | កាលបរិច្ឆេទ៖ | កាលបរិច្ឆេទ៖ |
| ការពិពណ៌នា៖ | ការពិពណ៌នា៖ | ការពិពណ៌នា៖ | ការពិពណ៌នា៖ |
| ចំនួន៖ | ចំនួន៖ | ចំនួន៖ | ចំនួន៖ |
| | សំភារៈ ឬឧបករណ៍ចិញ្ចឹមមាន់៖ | ទឹក ភ្លើង៖ | |
| | កាលបរិច្ឆេទ៖ | កាលបរិច្ឆេទ៖ | |
| | ការពិពណ៌នា៖ | ការពិពណ៌នា៖ | |
| | ចំនួន៖ | ចំនួន៖ | |

### ៦.៨ ទម្រង់បញ្ជីការប្រចាំឆ្នាំ សម្រាប់ផលិតកម្មមាន់

**តារាងបញ្ជីការប្រចាំឆ្នាំ សម្រាប់ផលិតកម្មមាន់**

**ឈ្មោះម្ចាស់កសិដ្ឋាន** ____ ____ **គ្រោងបញ្ជីការសម្រាប់ឆ្នាំ** ____________________

| ប្រភេទ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **A. ចំណូល** | | | | | | | | | | | | | |
| លក់មាន់សាច់ | | | | | | | | | | | | | |
| លក់ពងមាន់ | | | | | | | | | | | | | |
| លក់កូនមាន់ | | | | | | | | | | | | | |
| លក់មេពូជ | | | | | | | | | | | | | |
| លក់លាមកមាន់ | | | | | | | | | | | | | |
| ចំណូលផ្សេងៗ | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| **សរុបចំណូលប្រចាំខែ** | | | | | | | | | | | | | |
| **B. ចំណាយមុនពេលលក់មាន់** | | | | | | | | | | | | | |
| ចំណីក្រុមហ៊ុន | | | | | | | | | | | | | |
| ចុងអង្ករ | | | | | | | | | | | | | |
| កន្ទក់ | | | | | | | | | | | | | |
| ពោត | | | | | | | | | | | | | |
| ទ្រូង | | | | | | | | | | | | | |
| ពូជកូនមាន់ | | | | | | | | | | | | | |
| ទៃម៉ូម៉ែត្រវាស់សីតុណ្ហភាព | | | | | | | | | | | | | |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| វ៉ាក់សាំង | | | | | | | | | | | | |
| *សរុបរង ចំណាយមុនពេលប្រមូលផល* | | | | | | | | | | | | |
| **C. ចំណាយអំឡុង និងក្រោយពេលប្រមូលផល** | | | | | | | | | | | | |
| ថ្នាំបាញ់សម្លាប់មេរោគ | | | | | | | | | | | | |
| កំបោសរសម្លាប់មេរោគ | | | | | | | | | | | | |
| ចំណាយជួសជុលសម្ភារៈកសិដ្ឋាន | | | | | | | | | | | | |
| ការធ្វើទីផ្សារ( ការលក់ )និងចែកចាយ | | | | | | | | | | | | |
| *សរុបរងអំឡុងពេល និងក្រោយប្រមូលផល* | | | | | | | | | | | | |
| **D. ចំណាយលើចំណាត់ការទូទៅក្នុងកសិដ្ឋាន** | | | | | | | | | | | | |
| ថៃទាំសំភារៈឬឧបករណ៏ | | | | | | | | | | | | |
| អគ្គិសនី ទឹក | | | | | | | | | | | | |
| ការប្រាក់ | | | | | | | | | | | | |
| ផ្សេងៗ | | | | | | | | | | | | |
| **សរុបរង ចំណាយ** | | | | | | | | | | | | |
| **សរុបចំណាយប្រចាំខែ (B+C+D)** | | | | | | | | | | | | |
| **E. ចំណេញសុទ្ធប្រចាំឆ្នាំ** | | | | | | | | | | | | |

| | |
|---|---|
| **បរិយាយ** | |
| ចំណូលសរុបប្រចាំឆ្នាំ | |
| ចំណាយសរុបប្រចាំឆ្នាំ | |
| ចំណេញសុទ្ធ=ចំណូលសរុប-ចំណាយសរុប | |

សំគាល់៖ ថវិកាជាខ្មែររៀល

## ៦.៦ ទម្រង់កត់ត្រាថវិកា សម្រាប់វដ្តផលិតកម្មមាន់

ទម្រង់កត់ត្រាថវិកា សម្រាប់វដ្តផលិតកម្មមាន់

| ប្រភេទ | ចំណាយជាក់ស្តែងក្នុងវគ្គមុន(រៀល) | ថវិកាប៉ាន់ស្មាន (រៀល) | ចំណាយជាក់ស្តែង (រៀល) | ភាពខុសគ្នា (រៀល) |
|---|---|---|---|---|
| ចំណូល | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| ចំណូលសរុប | | | | |
| ចំណាយ | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| ចំណាយសរុប | | | | |
| | | | | |
| ចំណេញសុទ្ធ=(ចំណូល-ចំណាយ) | | | | |



ស្កេន QR កូដ
សម្រាប់ព័ត៌មានបន្ថែម